41 (5

៥

# កម្ពុជសុរិយា

គ្រួមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

អត្ថបទ — ផ្នែកសាសនា — ទំព័រ

១— សេចក្ដីក្លាហាន សហ. ផេង ជ្រីវ រៀបរៀង . . . . ៤៦៧

២— រឿងសុតនបណ្ឌិត សហ. ហេង សមអាន នាយទាហានរងកង យោធពលខេមរភូមិន្ទ រៀបរៀង . . . . . . ៤៧៤

## ផ្នែកអក្សរសាស្ត្រ

៣— វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង ខាត់ . . . . ៤៨៩

៤— វប្បធម៌ មន-ខ្មែរ សហ. ឌឹក-គាម រៀបរៀង . . . . ៤៩៣

៥— រឿងសាមកុក (ត) ឧកញ៉ានូ-កន ប្រែរៀបរៀង . . . . ៥១០

៦— រឿងព្រោះភ្លាក់នាវាដោយខ្យល់ព្យុះ សហជីវិន ពេជ-សល់ ប្រែរៀបរៀង ៥២១

## ផ្នែកកំណត់-ប្រវត្តិការណ៍

៧— ពិធីប្រគល់ព្រះត្រៃបិដកខ្មែរ ជូនចំពោះមជ្ឈមណ្ឌលពុទ្ធសាសនា នៅក្រុងហាលេ សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ . . . ៥៣៩

៨— ពិធីនមស្ការសក្យមុនីចេតិយ . . . . . . ៥៤២

៩— សេចក្ដីអំពាវនាវ នៃវិទ្យាឋានពុទ្ធសាសនបណ្ឌិត្យ . . . ៥៥១

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០៛០០ ។

## ផ្នែកសាសនា

| | |
|---|---|
| ពាក្យឃាត់មិនឲ្យ | ធ្វើការអាក្រក់ |
| ជាការណាមក | ឲ្យធ្វើល្អទៅ, |
| ឲ្យដុសខាត់ចិត្ត | កុំឲ្យហ្មងសៅ |
| បីនេះលោកហៅ | ពុទ្ធសាសនា ។ |

ប. ព

# សេចក្ដីក្លាហាន

ពាក្យថា "ក្លាហាន" នេះ ជាកម្លាំងចិត្តមួយ ដែលអាចតទល់ប្រឆាំងនឹងបច្ចាមិត្រគ្រប់បែបយ៉ាង ។ កម្លាំងចិត្តនេះ ត្រូវបានទុកជាគុណសម្បត្តិដ៏កម្រមួយ បណ្ដាគុណសម្បត្តិទាំងឡាយនៃមនុស្សទូទៅក្នុងលោក ដ្បិតដោយសារតែគុណសម្បត្តិនេះ មនុស្សអាចយកជោគជ័យលើធម្មជាតិបាន ហើយធ្វើខ្លួនឲ្យក្លាយទៅជា "សត្វមួយក្រុម" មានឋានៈសមល្មមគួរនឹងនាមរបស់ខ្លួនដែលហៅថា "មនុស្ស" នោះបាន ។

មានមនុស្សគេច្រើនណាស់ដែលនិយមពោលថា: ហេតុម្ដេចក៏មិនឃើញមានអត្តភ័យ មិនឃើញមានកើតសន្តិសុខ មិនឃើញមានកើតចម្រើន មិនឃើញមានមនុស្សល្អដទៃ ។ល។ ខ្លួននឹងគាលបញ្ចេញសេចក្ដីក្លាហានឲ្យអ្នកដទៃទាំងពួងយល់ ព្រមទាំងគោតស្ងប់ស្ងែងសរសើរខ្លួន នឹងរាប់អានផង ។

អ្នកដែលតាំងចិត្តដូច្នេះ ហៅថាអ្នកមានសេចក្ដីក្លាហានបានទេ ?

ត្រូវតែចាត់ទុកគេ ជាអ្នកមានសេចក្ដីក្លាហានដែរ ប៉ុន្តែ សេចក្ដីក្លាហានដូចបានពោលមកនេះ ហៅថា សេចក្ដីក្លាហានគ្រោតគ្រាត ជាសេចក្ដីក្លាហានប្រាសចាកភាពសុខុម ភាពហ្មត់ចត់ ។

សួរថា : បច្ចាមិត្ររបស់លោកិយ ដែលត្រូវយកសេចក្ដីក្លាហានទៅផ្ចាញ់ គឺអ្វីខ្លះ ?

ត្រង់នេះហើយជាចំណុចធំ ដែលសម្រាប់កាត់ឲ្យឃើញថា ណាជាសេចក្ដីក្លាហានគ្រោតគ្រាត ណាជាសេចក្ដីក្លាហានហ្មត់ចត់ ណាជាសេចក្ដីក្លាហានក្លែងក្លាយ ។

ឆ្លើយថា : បច្ចាមិត្ររបស់លោកិយ ដែលត្រូវយកសេចក្ដីក្លាហានមកផ្ចាញ់ មានពីរប្រការ គឺពាហិរបច្ចាមិត្រ ១ អជ្ឈត្តិកបច្ចាមិត្រមួយ ។

ចំពោះបច្ចាមិត្រទាំងពីរប្រការនេះ មានតែពាហិរបច្ចាមិត្រទេ ដែលមនុស្សខ្លះអាចយកសេចក្ដីក្លាហានរបស់ខ្លួន ទៅផ្ចាញ់បានយ៉ាងងាយ, រីអជ្ឈត្តិកបច្ចាមិត្រវិញ មានមនុស្សភាគតិចណាស់ ដែលអាចយកសេចក្ដីក្លាហានរបស់ខ្លួនទៅផ្ចាញ់បាន ។ បើពោលឲ្យចំទៅ គឺ មនុស្សគ្មានសេចក្ដីក្លាហានតែម្ដង ។

ឯអជ្ឈត្តិកបច្ចាមិត្រ គ្មានអ្វីក្រៅពីអកុសលធម៌ទេឡើយ ។

កូនសិស្សបានគេណែនាំយកចិត្តទុកសិក្សា ដឹងត្រូវទន្ទេញមេរៀន ព្រម

តាំងមេសូត្របង្ហើយ ស្រាប់តែឃើញគេបើកវិទ្យុទូរទស្សន៍ ក៏បញ្ឈប់កិច្ចសិក្សារបស់ខ្លួន ហើយមកអង្គុយមើលការបញ្ចាំងនោះទៅវិញ ។ នេះឈ្មោះថា ខ្វះសេចក្តីក្លាហាន ។ កូនសិស្សជំទង់បណ្តែតបណ្តោយឲ្យសេចក្តីស្នេហាញាំញី ហើយបោះបង់ចោលនូវកិច្ចសិក្សា ក៏ឈ្មោះថា ខ្វះសេចក្តីក្លាហាន ។ល។

គ្រូបង្រៀនបង្ហាត់សិស្សយ៉ាងខ្ជីខ្ជា មិនព្រមយកចិត្តទុកដាក់កែនិងពិនិត្យមើលកិច្ចការៈសិស្សឲ្យបានហ្មត់ចត់, ដេស្តីវាយសិស្សតាំងកម្រោលតាំងនេះ ក៏ឈ្មោះថា ខ្វះសេចក្តីក្លាហាន ។

ក្មេងបម្រើប្តីកូនចៅ មានៈធ្វើឲ្យបែកបានប្តីកែវ ។ល។ លុះចៅហ្វាយនាយឬមាតាបិតា ហៅមកសួរ បែរជាឆ្លើយបដិសេធ នេះក៏ហៅថា ខ្វះសេចក្តីក្លាហាន ។

មុខរបរឬកិច្ចការៈដែលខ្លួនត្រូវធ្វើរាល់ថ្ងៃ ខ្លួនមិនធ្វើដោយសតិសម្បជញ្ញៈព្រោះការខ្ជិលច្រអូស ហើយបែរទៅប្រព្រឹត្តចោរកម្ម នេះក៏ឈ្មោះថា ខ្វះសេចក្តីក្លាហាន ។ ភ្នាក់ងាររាជការដែលមិនបំពេញករណីយកិច្ចដែលច្បាប់បានតម្រូវទុក ឈ្មោះថា ខ្វះសេចក្តីក្លាហាន, ជាងសំណង់និងកម្មករដែលមិនបានបំពេញកិច្ចការឲ្យត្រឹមត្រូវតាមលក្ខណៈកម្រិតទុក និងឲ្យត្រឹមត្រូវតាមៈពេលម៉ោង គេហៅថា ខ្វះសេចក្តីក្លាហាន ។

ស្រែកលក់ដូរ ដែលបន្ទំយកវត្ថុមានគុណភាពអន់ ទៅលាយជាមួយវត្ថុមានគុណភាពល្អ ព្រោះតែចង់បានចំណេញច្រើន ឬដែលថ្លឹងបំបាត់ខ្នាតជញ្ជីង ឈ្មោះថា ខ្វះសេចក្តីក្លាហាន ។

ចៅក្រម ដែលកាត់សេចក្តីប្រកបដោយអគតិធម៌ ឈ្មោះថា ខ្វះសេចក្តីក្លាហាន ។ កូនក្តី ដែលនិយមយកសំណូកទៅជូនចៅក្រម ដើម្បីហេតុរបស់ខ្លួន ឈ្មោះថា ខ្វះសេចក្តីក្លាហាន ។

មនុស្សដែលបណ្តោយឲ្យអភិជ្ឈាចិត្តគ្របសង្កត់ ហើយប្រព្រឹត្តអំពើទុច្ចរិតគ្រប់បែបយ៉ាង ឈ្មោះថា ខ្វះសេចក្តីក្លាហាន ។ មនុស្សដែលបណ្តែតបណ្តោយឲ្យសេចក្តីស្នេហាញាំញី ហើយទៅប្រព្រឹត្តបរទារកម្មក្តី ទៅប្រព្រឹត្តរួមរ័កជាមួយកូនស្រីអ្នកដទៃក្តី ទៅរួមរ័កជាមួយស្រីពេស្យាក្តី ឈ្មោះថា ខ្វះសេចក្តីក្លាហាន ។

មនុស្ស ដោយចង់បានបុណ្យស័ក្តិពេក ដោយលោភអំណាចពេក ដោយប្រាថ្នាទ្រព្យធនពេក ហើយទៅឃោសនាមូលបង្កាច់កេរ្តិ៍អ្នកដទៃ ទៅទិញទឹកចិត្តអ្នកដទៃ ឬឲ្យអ្នកដទៃទិញខ្លួនដូចសត្វធាតុ នេះឈ្មោះថា ខ្វះសេចក្តីក្លាហាន ។

បើបព្វជិតណាមួយ ព្រោះតែចង់សប្បាយ ព្រោះតែចង់ហ៊ឺហាដូចគ្រហស្ថ ហើយភ្លេចគិតដល់វិន័យ ដល់ធម៌របស់ក្រុម ទៅប្រព្រឹត្តអំពើមិនគប្បី ឈ្មោះថា ខ្វះសេចក្តីក្លាហាន ។

រួមសេចក្ដីទៅ ឃើញថា មនុស្សក្នុងលោក ភាគច្រើនណាស់សុទ្ធសឹងជាអ្នកខ្សត់ខ្សោយ សុទ្ធសឹងជាអ្នកប្រកបដោយមហាទុព្វលភាពក្រៃលែង ចំពោះកាតព្វកិច្ចជីវិតរបស់ខ្លួនប្រចាំថ្ងៃ ជាកាតព្វកិច្ចដែលខ្លួនឥតយល់ពាល់តែសោះថា ត្រូវតែយកសេចក្ដីក្លាហានទៅប្រឆាំងទើបបាននោះ ៗ ហេតុដូច្នេះហើយ ទើបគេនិយមទុកជីវភាពនៃមនុស្សម្នាក់ ៗ ថាជាការប្រយុទ្ធ ៗ

តាមការសង្កេតឃើញថា មនុស្សខំប្រឹងធ្វើការប្រយុទ្ធអ៊ីចឹងមែនហើយ តែជាការប្រយុទ្ធផ្ទុយពីគោលច្បាប់របស់ខ្លួន ៗ ដូចម្ដេចក៏ថាខុសពីគោលច្បាប់ ? ព្រោះម្នាក់ ៗ មិនគិតប្រឆាំងនឹងបច្ចាមិត្តរបស់ខ្លួន បែរទៅខំប្រយុទ្ធវាយបែកជាមួយបច្ចាមិត្តរបស់ខ្លួនទៅវិញ ដើម្បីរកប្រយោជន៍ទម្លាក់មកលើខ្លួនតែម្នាក់ឯង ៗ ការស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន គឺជាច្បាប់ធម្មជាតិដ៏ពិតប្រាកដនៃមនុស្សគ្រប់រូប ៗ អ្នកណាដែលនិយាយថាកុំឲ្យស្វែងរកប្រយោជន៍ផ្ទាល់ខ្លួននោះ គឺយល់ខុសស្រឡះ ៗ តែសូមឲ្យការស្វែងរកប្រយោជន៍ផ្ទាល់ខ្លួននេះ ប្រព្រឹត្តទៅយ៉ាងណា កុំឲ្យក្បត់នឹងសិទ្ធិរបស់ខ្លួន ធ្វើយ៉ាងណា កុំឲ្យជះជាន់ ឬ គងទៅលើសិទ្ធិអ្នកដទៃ តែប៉ុណ្ណោះ ៗ

សេចក្ដីក្លាហានដែលឈ្មោះថាត្រឹមត្រូវ ហើយមិនធ្ងន់នោះ សំដៅទៅលើសេចក្ដីក្លាហានណាកើតឡើងហើយ ដើម្បីតទប់នឹងអកុសលចិត្តរបស់ខ្លួន ប្រាសចាកគំនិតលាក់ពុត ប្រាសចាកគំនិតកេងបន្លំ ៗ សព្វថ្ងៃមានមនុស្សភាគច្រើនរាប់មិនអស់ និយមយកសេចក្ដីក្លាហានក្លែងក្លាយមកអនុវត្ត ដើម្បីញ៉ាំងជីវភាព របស់ខ្លួន ឲ្យប្រព្រឹត្តទៅប្រសើរលើសគេ ហើយអ្នកផង ក៏នាំគ្នានិយម គោរពសរសើរ ព្រមទាំងលើកតម្កើង ថាជាមនុស្សឯកថែមទៀត, តែតាមការណ៍ពិតវិញ ទាំងអ្នកមានសេក្ដីក្លាហាននេះ ទាំងអ្នកគោរពសរសើរ សុទ្ធសឹងជាមនុស្សប្រភេទ "ដូនប័ង" ជាមនុស្សប្រភេទ "ពៀម" ៗ

ដូច្នេះ សេចក្ដីក្លាហាន ជាកុសលចេតសិកមួយ មិនងាយមនុស្សសាមញ្ញនឹងអាចបង្កើតឲ្យមានបានឡើយ ព្រោះសេចក្ដីក្លាហាននេះ គឺជាតួមហាគុណមួយកម្រនឹងរកបានណាស់ ៗ គឺសេចក្ដីក្លាហានដែលកើតឡើងសម្រាប់ប្រឆាំងនឹងអកុសលចិត្តរបស់អាត្មាប្រចាំថ្ងៃនេះហើយ ទើបឈ្មោះថា សេចក្ដីក្លាហានឯក ទើបឈ្មោះថា សេចក្ដីក្លាហានដ៏ហ្មត់ចត់បរិសុទ្ធ កម្ររកបាន ដែលអ្នកប្រាជ្ញទាំងឡាយក្នុងលោកមានព្រះបរមគ្រូសម្ពុទ្ធជាដើមទ្រង់និយមសរសើរនោះ ៗ

សរុបសេចក្ដីទៅ សេចក្ដីក្លាហាន ជាគុណធម៌មួយយ៉ាងប្រពៃសម្រាប់ឲ្យមនុស្សទុកប្រើប្រឆាំងតនឹងឧបសគ្គទាំងខាងក្រៅ ខាងក្នុង,

ឧបសគ្គខាងក្រៅ សំដៅទៅលើធម្មជាតិ តែឧបសគ្គនេះ ងាយនឹងប្រឆាំងណាស់ ឲ្យតែមនុស្សមានមនោព្យាយាមគ្រប់គ្រាន់ ព្រមទាំងមានសុធម្មៈផង ៗ ជាទីអវសាន ឧបសគ្គខាងក្នុង សំដៅទៅលើអកុសលចិត្តគ្រប់បែបយ៉ាង ៗ មនុស្សណា ដែលមានសេចក្តីក្លាហាន អាចប្រឆាំងនឹងអកុសលចិត្តបាន ទើបចាត់ទុកអ្នកនោះថា ជាមនុស្សឯកប្រសើរជាងគេ ៗ មនុស្សមានចិត្តទូន្មានបាន ទុកជាមនុស្សកម្រក្រៃលែង និងជាទីគោរពរាប់អាន និងកោតសរសើរ ពីសំណាក់គល្យាណជនទាំងឡាយ ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ៗ

ជាទីបញ្ចប់ អ្នកមានសេចក្តីក្លាហានក្នុងសង្គ្រាម ក្នុងអគ្គិភ័យ ក្នុងចោរកម្ម ៗ ល ៗ ក៏ទុកជាការណ៍គ្រាន់បើគួរសមឲ្យសរសើរបានខ្លះដែរ តែមិនត្រូវបានទទួលនាមបញ្ញត្តិថា ជាអ្នកក្លាហានដ៏មោះមុតបានទេ ព្រោះសេចក្តីក្លាហាននេះកើតឡើង ដោយពេលដោយខណៈ ហើយដោយសារការៈទាល់ច្រក ដោយសារគេបង្ខំ ឬដោយសារចំណង់ពួយខានពុំបានតែប៉ុណ្ណោះ ៗ ឯសេចក្តីក្លាហានខាងកម្ចាត់អកុសលចិត្ត ទើបចាត់ទុកជាសេចក្តីក្លាហានមែនទែន ជាសេចក្តីក្លាហានជាប់បញ្ញាចិត្តនិស្ស័យរបស់ខ្លួន ដូចព្រះអាទិត្យ ដែលដល់ពេលហើយ ត្រូវតែរះបញ្ចេញពន្លឺរស្មីបំភ្លឺលោក ទោះបីមានពពកខ្មៅ ឬមានភ្លៀងធ្លាក់និងព្យុះសង្ឃរាដូចម្តេចក្តី ៗ

# រឿងសុតនបណ្ឌិត

សហជីវិន ហោង សមអាង នាយទាហានរងកងយោធពលខេមរភូមិន្ទ

ធ្វើការនៅសេនាធិការយោធភូមិភាគទី ១

តែងនិងរៀបរៀង

ក្នុងកាលកន្លងយូរយារអង្វែងណាស់ទៅហើយ ព្រះសម្មាសម្ពុទ្ធ បរមសាស្តាចារ្យ ទ្រង់យោនយកកំណើតក្នុងត្រកូលកម្មករ ព្រះនាម សុតនបណ្ឌិត ប្រកបការងារស៊ីឈ្នួលលីសែងចិញ្ចឹមឪពុក-ម្តាយ នៅក្រុងពារាណសីនៃប្រទេសកាសី ។

កាលពីកុមារ មាតាបិតាខំប្រឹងអត់ធ្មត់ ធ្វើការស៊ីឈ្នួលគេទាំងយប់ទាំងថ្ងៃ យកប្រាក់ធ្វើសោហ៊ុយ បញ្ជូនឲ្យទៅសិក្សាសិល្បសាស្ត្រនៅសកលវិទ្យាល័យ នាក្រុងតក្កសិលា ដោយបិតាប្រកាន់គតិបុរាណ ថា បណ្ឌិតបុគ្គលដែល

គ្មានកូន ១

កូនស្លាប់ ១

កូនល្ងង់ ១

អ្នកគ្មានកូន និងកូនស្លាប់ហើយ ប្រសើរជាងកូនរស់នៅល្ងង់ខ្លៅ ព្រោះកូនស្លាប់ ធ្វើឲ្យឪពុកម្តាយកើតទុក្ខ អស់រយៈតែ ១ ខែ ឬ ២ ខែ ។ ចំណែកកូនល្ងង់ខ្លៅ ធ្វើឲ្យឪពុកម្តាយកើតទុក្ខអស់មួយជីវិត ។

សុភាសិត

មានកូនមិនឲ្យកូនសូត្ររៀន ចំណេះរៀនការនានា
មាតាលោកថាជាពៀរ បិតាទុកជាសត្រូវធំ ។
កូនពេញរូបពាលពាក់មិនឡើង ហៅថាមិនចេះក្នុងជំនុំ
ប្រៀបដូចកុកក្រោកចូលទ្រទំ កណ្ដាលជំនុំនៃពួកហង្ស ។

ដកស្រង់សុត្តន្តប្បិដក ជំពូកបណ្ឌិត

ក្រុងតក្កសិលា ជាក្រុងធំប្រជុំនៃវិជ្ជា មានអ្នកប្រាជ្ញជាបណ្ឌិតជាន់ខ្ពស់ជាច្រើន អាចទទួលបង្រៀនសិល្បសាស្ត្រគ្រប់យ៉ាង តាមបំណងសិស្សត្រូវការ ។ ស្ដេច, មន្ត្រី, គហបតី, អ្នកមាន, អ្នកក្រ ក្នុងដែននានា សូម្បីនៅឆ្ងាយប៉ុន្មានក៏ដោយ តែងបញ្ជូនបុត្ររបស់ខ្លួនឲ្យទៅសិក្សាក្នុងក្រុងនេះជាច្រើន ។

របៀបសូត្ររៀនមាន ២ បែបគឺ:

១. ត្រូវបង់ថ្លៃចំណៀមទម្លាប់;

២. មិនបង់ថ្លៃចំណៀមទម្លាប់ តែត្រូវធ្វើការគ្រប់ជំពូក ។

សុតនកុមារ បានសិក្សាក្នុងសកលវិទ្យាល័យ ដោយរបៀបទី ២ គឺស្នាក់នៅគេហដ្ឋាន មហាវិទ្យាធិការ ធ្វើការបម្រើតាមតែលោកប្រើ ។

ការសិក្សាចេះចប់ហើយ ក៏លាលោកសាស្ត្រាចារ្យនិងមិត្តរួមសាលាគ្រប់រូបណាមានគុណមិញ ធ្វើការសុំឈប់លាដើម្បីមកតាមផ្លូវឆ្ងាយ ថែរក្សាប៉ាក់·

ថ្មមិនដែលឃ្លើសចិត្ត ។

កាលនោះ ព្រះបាទព្រហ្មទត្តព្រះចៅក្រុងពារាណសី ស្ដេចចេញប្រពាតព្រៃព្រឹក្សា មួយអន្លើដោយសេវកាមាត្យជាច្រើនតាមដង្ហែជាព្រះកិត្តិយស, លុះយានចូលដល់ព្រៃជ្រៅ ស្ដេចត្រាស់បង្គាប់ឲ្យសេវកាមាត្យៈចោមព័ទ្ធជុំវិញព្រៃវាយបង្អើលសត្វ ហើយទ្រង់ផ្ដាំថាបើម្រឹគរត់រួចចំពោះមុខអ្នកណា អ្នកនោះត្រូវសង ។ ក្នុងព្រៃនោះមានប្រើសមួយដេកនៅ, កាលបើឃើញមនុស្សវាយព្រៃឈរចោមព័ទ្ធ គិតភ័យស្លុតរត់ដោះទម្លាយចំពោះព្រះភក្ត្រព្រះមហាក្សត្ររួចទៅ, ព្រះចៅទ្រង់ខត្តិយមានះលេះលោងគង់លើអាជានេយ្យចេញតាមម្រឹគ កាប់នឹងព្រះខ័នដាច់ជា ២ កំណាត់ យកសាច់ត្រឡប់មកវិញ ។ ដោយអស់ព្រះកាយពលខ្លាំងពេក ស្ដេចចូលឈប់សម្រាកក្រោមម្លប់សាខាដើមជ្រៃ ។ ពេលនោះ មក្ខទេវយក្ខអ្នករក្សាដើមជ្រៃចាប់ព្រះអង្គ ហើយគំរាមថា "អ្នកឯងត្រូវបានជាអាហាររបស់យើង", ព្រះរាជាតក់ស្លុតព្រះទ័យភ័យណាស់អង្វរថា "បពិត្រមហាយក្ស អ្នកបរិភោគតែម្ដងទេឬក៏រាល់ថ្ងៃ"? យក្សប្រាប់ថា "បើបានរាល់ថ្ងៃ យើងបរិភោគរាល់ថ្ងៃ", ព្រះរាជាតបថា "បើដូច្នោះ ថ្ងៃនេះ អ្នកបរិភោគសាច់ប្រើសចុះ, ចាប់ពីថ្ងៃស្អែកទៅ យើងនឹងបញ្ជូនមនុស្សម្នាក់នាំអាហារ ១ សម្រាប់ឲ្យអ្នករៀងរាល់ៗថ្ងៃ" ។ យក្សថា "បើមិនបញ្ជូនមនុស្សម្នាក់និងអាហារ ១ សម្រាប់ទេ យើងនឹងចូលទៅចាប់បរិភោគទាំងបុត្តផង",

ព្រះរាជាយល់ព្រមជាមួយយក្សហើយ ក៏យាងចូលព្រះរាជវាំង ។ ចាត់រាជបុរសឲ្យដោះយកមនុស្សទោសពីក្នុងគុក ១ ថ្ងៃម្នាក់ ៗ ឲ្យនាំយកសម្រាប់ទៅឲ្យមគ្គទេវយក្សជាអចិន្ត្រៃយ៍ ទាល់តែអស់មនុស្សទោស ។ កាលបើទ្រង់ជ្រាបថាអស់មនុស្សទោសហើយ ទើបទ្រង់ត្រាស់បង្គាប់ឲ្យយកប្រាក់ ១.០០០ កហាបណៈដាក់លើដំរីមង្គល ឲ្យមន្ត្រីវាយគងស្រែកប្រកាសថា “បើនរណា អាចនាំសម្រាប់ទៅឲ្យយក្សបាន, នរនោះ ចូរមកទទួលយកប្រាក់ ១.០០០ កហាបណៈនេះចុះ” ។

កាលនោះ សុតនបណ្ឌិតអ្នកចិញ្ចឹមមាតាបិតាបានស្ដាប់រាជប្រកាសហើយ ក៏ចូលទៅទទួលយកប្រាក់ ១.០០០ កហាបណៈនោះទៅជូនមាតាបិតាហើយជម្រាបថា “លោកឪពុក-ម្ដាយ! កូនសូមលាលោកមានគុណថ្ងៃនេះហើយ នាំសម្រាប់ទៅឲ្យយក្ស ដើម្បីទូន្មានយក្សឲ្យលះបង់អំពើទុច្ចរិតផង” ។ ឪពុកម្ដាយតបថា “កូនអើយកុំទៅប្រដៅយក្ស មិនបានទេ! វាមិនស្ដាប់កូនទេ! វាមុខតែវាស៊ីកូនឯងមិនខានទេ ណាកូនប្រុស!” ។

សុតនបណ្ឌិតជម្រាបថា “លោកអ្នកមានគុណ ជាទីគោរព! សូមកុំព្រួយឲ្យសោះ, កូនជាអ្នកទូន្មានយក្សឲ្យបានរួចមិនខាន, បើវាមិនស្ដាប់ទេ កូននឹងសម្លាប់វាភ្លាម ដើម្បីជាតិរបស់យើងរស់នៅ ។ បើផ្ទុយទៅវិញ កូនត្រូវបរាជ័យ ក៏លោកឪពុកម្ដាយបានប្រាក់ ១.០០០ កហាបណៈដែរ, សូមលោកឪពុកម្ដាយជ្រាបថា “យុទ្ធសិល្បករ មានចិត្តបម្រើផលប្រយោជន៍

ជាតិ មិនត្រូវខ្លាចគ្រោះថ្នាក់ថ្នាក់មកលើខ្លួនឡើយ ។ គេត្រូវទទួលទុក្ខមុន គេនិងសុខក្រោយគេ ។ ទោះជាមានឧបសគ្គយ៉ាងណា ក៏កូនត្រូវតែចេញទៅបង្ក្រាបយក្ខ ជាដាច់ខាត" ។ ឪពុកម្ដាយយល់ព្រមតាមសុំហើយថា "ទៅចុះណាកូនប្រុស! សូមឲ្យកូនមានជ័យជម្នះ! សូមគុណព្រះរតនត្រ័យជួយកូន!" ។ ព្រះពោធិសត្វសំពះលាម្ដាយឪពុកហើយ ក៏ឲ្យបុរសនាំទៅថ្វាយបង្គំព្រះមហាក្សត្រក្នុងព្រះរាជវាំង ។ ព្រះរាជាត្រាស់សួរថា "អ្នកនាំសម្រាប់ទៅឲ្យយក្ខ តើចង់បានអ្វីយកទៅខ្លះ?" ។ ព្រះពោធិសត្វក្រាបទូលថា "ទូលព្រះបង្គំចង់បានសុពណ៌បាទុក ស្វេតឆត្រ និងព្រះខ័ន យកទៅជាមួយ" ។ ព្រះរាជា– "ហេតុអ្វីទើបអ្នកចង់បានរបស់ទាំងនេះយកទៅជាមួយ?", ព្រះពោធិសត្វ– "បពិត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានជាទូលព្រះបង្គំចង់បានរបស់ទាំងនេះ ជាការសម្ងាត់របស់ទូលព្រះបង្គំផង តែសូមព្រះអង្គទ្រង់ជ្រាបថា បំណងរបស់ទូលព្រះបង្គំ គឺចង់ទូន្មានយក្ខឲ្យបានស្លូត, តែបើវាមិនតាមដំបូន្មានទេ ទូលព្រះបង្គំសម្លាប់ភ្លាម ។ ព្រះរាជា– "ម្នាលបណ្ឌិតកុមារ! យក្ខមានឥទ្ធិឫទ្ធិខ្លាំងពូកែណាស់, មិនអាចប្រយុទ្ធទប់ទល់នឹងវាបានឡើយ" ។ ព្រះពោធិសត្វ– "បពិត្រព្រះមហារាជ, ទូលព្រះបង្គំបានរៀបចំចិត្តប្ដូរជីវិតប្រយុទ្ធនឹងយក្ខហើយ, សូមព្រះអង្គកុំទ្រង់បារម្ភ ព្រោះទូលព្រះបង្គំ បានសិក្សាយុទ្ធសិល្បដល់ថ្នាក់កំពូល, ទោះយក្ខក្ដី នាគក្ដី គ្រុឌក្ដី មិនអាចប្រយុទ្ធទប់ទល់នឹងទូល

ព្រះបង្គំបានឡើយ" ។ ព្រះរាជា– "សាធុ! សាធុ! ប្រពៃណាស់! តើលោកចង់បានអ្វីខ្លះទៀត" ។ ព្រះពោធិសត្វ– "សូមព្រះរាជទាន មនុស្សកាន់សុវណ្ណភាជន៍តាមទូលព្រះបង្គំ" ។ ព្រះរាជា ក៏ទ្រង់យល់ព្រម ហើយទ្រង់មានព្រះបន្ទូលថា "សូមលោកអញ្ជើញទៅឲ្យមានជ័យជម្នះ, ខ្ញុំនឹងប្រជាជនទាំងអស់ មានសង្ឃឹមនឹងចាំទទួលសេចក្ដីសុខសាន្តពីលោក" ។ ព្រះពោធិសត្វ ក្រាបថ្វាយបង្គំលាព្រះរាជា នាំបុរសអ្នកបម្រើទៅដើមជ្រៃ ឲ្យអ្នកបម្រើឈរចាំ នៅឆ្ងាយពីដើមជ្រៃ ។ ព្រះពោធិសត្វ ពាក់ស្បែកជើងមាស បាំងឆត្រស កាន់ព្រះខ័ននិងភាជន៍មាស ដើរចូលយ៉ាងរហ័ស ដល់ហើយឈរក្រោមម្លប់ជ្រៃ យកចុងព្រះខ័នចុកភាជន៍នោះ ហុចទៅឲ្យយក្ខ ។

តាមពិត យក្ខនោះ បើនរណាចូលទៅឈរក្រោមម្លប់ជ្រៃ ទើបយក្ខហ៊ានចាប់ខាំនោះបរិភោគ ។ ព្រះពោធិសត្វដឹងរឿងនោះ ទើបមិនចូលក្នុងម្លប់ជ្រៃរបស់យក្ខ ។ មគ្គទេវយក្ខ ក៏ល្បួងលោមថា "ម្នាលបុរស! ចូរអ្នកមកបរិភោគជាម្ហូបយើង" ។ ព្រះពោធិសត្វឆ្លើយថា "ម្នាលមគ្គទេវយក្ខ យើងស្គាល់ពុតកំហូចរបស់អ្នកហើយ, អ្នកមិនបាច់ល្បួងយើងទេ, អ្នកស្គាល់យើងទេ? យើងឈ្មោះ សុតនបណ្ឌិត ជាអ្នកចិញ្ចឹមមាតាបិតា [illegible] ជាយុទ្ធសិល្បករថ្នាក់កំពូល ។ បើអ្នកចង់បរិភោគយើង ក៏មិនបាន ព្រោះមកនេះមិនបានជាន់លើដីអ្នក មិនបានជ្រកក្រោម

ម្លប់ព្រៃអ្នក, យើងឈរជាន់លើសុពណ៌បាទុករបស់យើង! យើងឈរតែក្រោមម្លប់ឆត្ររបស់យើង ។ យើងមកនេះបានប្រុងប្រយ័ត្នហើយ យើងប៉ងប្រយុទ្ធជាមួយអ្នកឲ្យដឹងថ្វីដៃគ្នាក្នុងគ្រានេះឯង" ។ មគ្គទេវយក្ខបានស្តាប់ មានចិត្តជ្រះថ្លា គិតថាបុរសនេះមានប្រាជ្ញា ពោលពាក្យពីរោះគួរចង់ស្តាប់ ។

លុះយក្ខបរិភោគអាហាររួចហើយ ក៏និយាយទៅកាន់ព្រះពោធិសត្វថា "ម្នាលយុវជន! ចូរអ្នកមកយកភាជន៍របស់អ្នកត្រឡប់ទៅវិញចុះ" ។ ព្រះពោធិសត្វសួរថា "ម្នាលមគ្គទេវយក្ស! ចុះមនុស្សនាំសម្រាប់មកឲ្យអ្នក ត្រូវអ្នកចាប់គេស៊ីជាងមួយឆ្នាំហើយនោះ តើត្រូវគិតដូចម្ដេច?" ។ មគ្គទេវ-យក្ខ- "រឿងនោះ ជារឿងរបស់យើងជាមួយព្រះរាជា គ្មានពាក់ព័ន្ធនឹងអ្នកទេ ព្រោះព្រះរាជាបានសន្យាជាមួយយើងថា ឲ្យមនុស្សម្នាក់នឹងអាហារ ១ សម្រាប់យកមកឲ្យយើង" ។ ព្រះពោធិសត្វ– "ពិតមែនហើយមហាយក្ខ! តែថាយើងជាពលរដ្ឋមួយរូប មិនបណ្ដោយឲ្យអ្នកឯងរឹបជាន់ស៊ីគេតាំងអំ-ណាចទេ, ព្រះរាជារបស់យើង បានបញ្ជូនមនុស្សនឹងសម្រាប់មកឲ្យអ្នកជាច្រើនណាស់ ហួសពីល្មមទៅហើយ គួរណាស់តែអ្នកបរិភោគតែអាហារបានហើយ, មិនសមបើហានរំលោភ ចាប់អ្នកនាំសម្រាប់បរិភោគទៀតសោះ ។ ម្នាលមគ្គទេវយក្ខ! អ្នកដឹងទេ ជាតិមុនអ្នកប្រព្រឹត្តអំពើបាប ទើបជាតិនេះ អ្នកកើតជាយក្ខ រង់ទុក្ខវេទនានៅយាមដើមជ្រៃ ។ ហេតុនេះ ចូរ

អ្នកកុំប្រព្រឹត្តអំពើបាបបញ្ចវេរ គឺ មិនសម្លាប់មនុស្ស សត្វជាដើម ហើយត្រូវប្រព្រឹត្តនូវអំពើជាកុសល ចាប់ពីថ្ងៃនេះទៅ ទើបបានកើតជាមនុស្សមានសេរីភាពបរិបូរ" ។ មគ្គទេវយក្ខ "បពិត្រមហាបុរស! សូមលោកសម្តែងអំពីបុណ្យបាប ឲ្យបានពិស្តារឲ្យទាន ដោយអនុគ្រោះ" ។ ព្រះពោធិសត្វសម្តែងថា

ម្នាលមគ្គទេវយក្ខ ចូរអ្នកលះបង់អំពើបាប ព្រោះអំពើបាបពុំមែនជាអំពើនាំមកនូវសេចក្ដីសុខត្រជាក់ឡើយ សុទ្ធតែជាអំពើនាំមកឲ្យអ្នកធ្វើមានសេចក្ដីក្ដៅក្រហាយ តាំងពីមានជីវិតរស់នៅ រហូតដល់ពេលស្លាប់ទៅ ក៏ត្រូវទៅកើតក្នុងអបាយភូមិទាំង ៤ ណាមួយថែមទៀត ដូចព្រះពុទ្ធដីកាថា ទុក្ខោ បាបស្ស ឧច្ចយោ ការសន្សំនូវបាប ជាហេតុនាំមកនូវទុក្ខ បាបានំ អករណំ សុខំ ការមិនធ្វើបាបទាំងឡាយនាំមកនូវសេចក្ដីសុខ ។

ម្នាលយក្ខ! ការលះបង់អំពើបាប ឈ្មោះថាអំពើល្អ ជាអំពើឲ្យអភ័យដល់ជីវិត, ទ្រព្យសម្បត្តិ, ទីកន្លែងនិងទឹកដីអ្នកដទៃ ឈ្មោះថាជាអំពើល្អ ដើម្បីសេចក្ដីសុខ-ចម្រើន ដល់អ្នកដទៃផង ដល់ខ្លួនឯងផង ។ ការលះបង់អំពើបាប ជាផ្លូវនាំសេចក្ដីសុខ-ចម្រើន តាំងពីមានជីវិតរហូតមរណកាល ក៏ត្រូវទៅកើតក្នុងសុគតិភព ។

ម្នាលយក្ខ! បុណ្យនិងបាប កើតមកអំពីបុគ្គលអ្នកធ្វើ ពុំមែន

កើតដោយនរណាមួយ ដែលសក្តិសិទ្ធិប្រគល់ឲ្យ ឬខ្លួន យកបាបជំនួសអ្នកធ្វើបានឡើយ ។ បុណ្យបាប គ្មានពិធីអគ្គិភេទបន្សុទ្ធឲ្យរួចចាកបាប ឬឲ្យបានបុណ្យទេ គឺថា ពុំមានករណីយកិច្ចអនុញ្ញាត ឲ្យធ្វើបុណ្យលាងបាបដោយការលុតក្រាបសំពះសុំអង្វរនោះឡើយ ដូចពុទ្ធភាសិតថា

អត្តនា វ កតំ បាបំ អត្តនា សង្កិលិស្សតិ
អត្តនា អកតំ បាបំ អត្តនា វ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។

បុគ្គលធ្វើបាបហើយ ដោយខ្លួនឯង រមែងសៅហ្មងដោយខ្លួនឯង បុគ្គលមិនធ្វើបាបហើយ ដោយខ្លួនឯង រមែងបរិសុទ្ធ ដោយខ្លួនឯង, សេចក្តីបរិសុទ្ធ និងមិនបរិសុទ្ធ ឲ្យផលចំពោះខ្លួន, បុគ្គលដទៃ មិនអាចញុំាងបុគ្គលដទៃឲ្យបរិសុទ្ធបានទេ ។

បាបនិងបុណ្យដែលបុគ្គលណាធ្វើដោយផ្ទាល់ខ្លួន បុគ្គលនោះ ត្រូវបានទទួលផលរបស់បាបនិងបុណ្យ ដោយផ្ទាល់ខ្លួនវិញដែរ ពុំមានព្រះអាទិទេព ឬវត្ថុសក្តិសិទ្ធិណាមួយក្នុងលោក អាចជួយកំចាត់ផលទោសពៀរជំនួសអ្នកធ្វើ ឬដោយប្រោសប្រណីបានឡើយ ។

ម្នាលយក្ខ! កាលអ្នកពិចារណាឃើញទោស នៃការប្រព្រឹត្តអាក្រក់, ឃើញអានិសង្ស នៃការប្រព្រឹត្តល្អហើយ គប្បីលះបង់នូវទុច្ចរិត វៀរចាកអំពើបាបអកុសល គប្បីចម្រើនសុចរិត បំពេញកុសលកម្ម ឲ្យមានបរិបូណ៌ឡើងក្នុងសន្តាន ។ ការវៀរចាកអំពើបាប ដោយកាយវាចាចិត្តហើយ ឈ្មោះថាជាអ្នកជម្រះខ្លួនប្រាណ ឲ្យជ្រះមន្ទិលគ្រោតគ្រាត ជាអ្នកមានកាយវាចាចិត្តបរិសុទ្ធស្អាត គួរដល់ភាវនាកម្ម ប្រៀបដូចសាច់សំពត់ស្អាត អាចទទួលនូវការជ្រលក់ ដោយពណ៌ផ្សេង ៗ បានដោយល្អ ។

ម្នាលយក្ខ! ចូរអ្នក បំពេញកុសលឲ្យបរិបូណ៌ឡើង, ពាក្យថាកុសលនេះ បានដល់អំពើល្អទាំងអស់ ដែលលោកសង្គ្រោះយក សុចរិតធម៌ និងបុញ្ញកម្មផ្សេង ៗ មានការធ្វើទានរក្សាសីលជាដើម ។ ការដែលធ្វើ គ្រាន់តែលះបាបកម្មទុកជាកិច្ចវត្តដ៏ប្រសើរដែរហើយ ប៉ុន្តែមិនទាន់សម្រេចត្រឹមនេះទេ ត្រូវធ្វើសេចក្តីល្អ ដោយញុំាងកុសលកម្ម ឲ្យកើតឡើងក្នុងសន្តាន ជំនួសសេចក្តីអាក្រក់ ដែលលះបានហើយថែមឡើងទៀត ។

ម្នាលយក្ខ! ដើម្បីអប់រំកាយវាចាចិត្ត ឲ្យមានសីលធម៌ ត្រូវបំពេញកុសលធម៌ឲ្យបរិបូណ៌ឡើង ព្រោះកុសលធម៌ ជា

ឧបាយនាំមកនូវសេចក្ដីសុខសប្បាយរីករាយ តាំងពីលោក
នេះ រហូតលោកខាងមុខ ដូចពុទ្ធភាសិតថា

ឥធ មោទតិ បេច្ច មោទតិ
កតបុញ្ញោ ឧភយត្ថ មោទតិ ។

បុគ្គលអ្នកមានបុណ្យធ្វើហើយ រមែងរីករាយត្រេកអរ ក្នុងលោកទាំងពីរ គឺរីករាយក្នុងលោកនេះ លុះលះលោកនេះទៅហើយ ក៏រមែងរីករាយទៀត ។

ម្នាលយក្ខ! ការញុំាងកុសលឲ្យកើតឡើង បានដល់ការបណ្ដុះ បង្កើត សន្សំរឿយៗ ឲ្យកើតមានឡើង ដោយការបំពេញទាន, រក្សាសីល និងចម្រើនសមថកម្មដ្ឋាន ដើម្បីរម្ងាប់នូវនីវរណូបក្កិលេសទាំង ៥ គឺ:

១- កាមច្ឆន្ទៈ សេចក្ដីប្រាថ្នា ស្រឡាញ់ជាប់ក្នុងកាម,
២- ព្យាបាទៈ ការញុំាងប្រយោជន៍ និងសេចក្ដីសុខអ្នកដទៃឲ្យវិនាស,
៣- ថីនមិទ្ធៈ សេចក្ដីខ្ជិលច្រអូស,
៤- ឧទ្ធច្ចកុក្កុច្ចៈ សេចក្ដីរាយមាយក្ដៅក្រហាយ,
៥- វិចិកិច្ឆា សេចក្ដីសង្ស័យ ។

ដើម្បីបែរឈមទៅរកប្រយោជន៍ និងសេចក្ដីសុខ ក្នុងមនុស្សលោក និងទេវលោក ។

ម្នាលមគ្គទេវយក្ខ! ចូរអ្នកលះបង់នូវអំពើអកុសលចេញ, ចូរអ្នកបំពេញអំពើកុសលឡើង ។

ព្រះពោធិសត្វ សម្តែងសង្ខេបតែប៉ុណ្ណោះ មគ្គទេវយក្ខស្តាប់ហើយក៏កើតចិត្តជ្រះថ្លា លុតជង្គង់សំពះហើយពោលថា "បពិត្រមហាបុរស ជាទីគោរពស្មើជីវិត! សូមមេត្តាអនុគ្រោះទទួលខ្ញុំបាទជាសិស្ស ប្រៀនប្រដៅឲ្យបាន ខ្ញុំបាទល្ងិតល្ងង់ខ្លៅណាស់ ។ បពិត្រមហាបុរស! ចាប់ពីថ្ងៃនេះទៅ ខ្ញុំបាទ ទទួលស្តាប់តាមឱវាទដ៏មានខ្លឹមសារពីរោះនេះ ហើយនឹងវៀរចាកអំពើអកុសល តម្កល់ខ្លួនបំពេញអំពើកុសល, មហាបុរសជឿខ្ញុំបាទចុះ ខ្ញុំបាទឈប់ដើរដេញដាច់សង្កត់សង្កិន រំលោភបំពានលើសិទ្ធិសេរីភាពអ្នកខ្សត់ខ្សោយ ហើយនឹងជួយការពារគាំទ្រអ្នកតូចតាច ឲ្យអស់សមត្ថភាពនិងកម្លាំងកាយចិត្ត" ។ ព្រះពោធិសត្វដឹងថា យក្ខលុះដោយដំបូន្មានហើយ លោកត្រេកអរណាស់ ក៏ពោលថា "ម្នាលមគ្គទេវយក្ខមានអាយុ! ប្រពៃណាស់ ប្រពៃណាស់ ប្រពៃណាស់ ចូរចម្រើនដល់អ្នក ។

ព្រះពោធិសត្វ នាំមគ្គទេវយក្ខទៅក្រាបថ្វាយបង្គំ ព្រះមហាក្សត្រទូលតាមដំណើរហេតុការណ៍ថ្វាយទ្រង់ព្រះសណ្តាប់ ។ ព្រះចៅ ទ្រង់មានព្រះទ័យសោមនស្សក្រៃលែងចំពោះព្រះពោធិសត្វ ។ ព្រះចៅ ទ្រង់ព្រះចិន្តាថា "បុរជននេះ មានប្រាជ្ញាឈ្លាសពិចក្ខ មានយុទ្ធសិល្បដល់កម្រិតកំពូល, អក្សរសាស្ត្រ និងធម្មសាស្ត្រដល់ថ្នាក់បណ្ឌិតហើយ, មានស្វាមីភក្តិចំពោះ

ជាតិ សាសនា ព្រះរាជបល្ល័ង្ក និងវត្តរជនណាប្រៀបឲ្យប្រហែលពុំបានឡើយ, គួរលើកតម្កើងជាមន្ត្រីធំ ទើបសមនឹងគុណូបការៈ ដែលបានធ្វើហើយចំពោះជាតិ" ទ្រង់ព្រះចិន្តាដូចនេះហើយ ក៏ត្រាស់បង្គាប់ឲ្យរាជ-អាមាត្យនាំព្រះពោធិសត្វ និងយក្ខទៅសម្រាក ។ ទើបទ្រង់ប្រជុំអ្នកប្រាជ្ញរាជបណ្ឌិត មហាបុរោហិតព្រឹទ្ធហោរា ព្រឹទ្ធសភានិងមន្ត្រីធំៗទាំងអស់ក្នុងព្រះរាជាណាចក្រ លុះជួបជុំហើយទ្រង់ត្រាស់ថា "ថ្ងៃនេះ អស់លោក! ជាថ្ងៃជោគជ័យមហាប្រសើរ ដែលត្រូវកត់ចំណាំទុកក្នុងក្រាំងមាសនៃប្រវត្តិសាស្ត្រប្រទេសយើង, ជ័យជម្នះនេះ គឺ មហាវីរបុរសនាមសុតនបណ្ឌិត បានស្ម័យប្រទេសជាតិផុតពីមរណភាព ដឹកនាំយក្ខឲ្យលុះតាមដំបូន្មានដ៏ប្រពៃរបស់លោក; គុណូបការៈនេះ គួរតែងតាំងលោក ក្នុងតំណែងជាមន្ត្រីធំ, តើអស់លោកយល់យ៉ាងណា?" ។ អង្គប្រជុំយល់ព្រមដោយរីករាយ ។ លោកប្រធានព្រឹទ្ធសភាក្រាបទូលថា "បពិត្រព្រះករុណាថ្លៃវិសេស ប្រទេសជាតិយើង បើកុំតែបានមហាបុរសនេះ, យក្ខរាទិនចូលមកកាត់ក្បាល គួរណាស់ព្រះអង្គប្រទានតំណែងជា "មហាឧបរាជ" ទើបសមនឹងគុណូបការៈនេះ ក្រាបទូល ។ បន្ទាប់មកលោកអគ្គនាយកក្រ-សួងនានាក្នុងរាជវាំង ក្រាបបង្គំទូលថា "បពិត្រព្រះសម្មតិទេព, តាមយោ-បល់ទូលព្រះបង្គំជាខ្ញុំយល់ថា វាសនាអនាគតនៃប្រទេសកាសី ពឹងផ្អែកផ្ញើលើមហាបុរសនេះពិតប្រាកដ ដើម្បីដឹកនាំប្រទេសទៅកាន់សន្តិភាព

បម្រើនូវរឿង, ដូចនេះទូលព្រះបង្គំជាខ្ញុំ សូមស្នើព្រះរាជយោបល់ សូមព្រះអង្គតាំងជាព្រះរជ្ជទាយាទ និងរៀបអភិសេកព្រះរាជធីតានៅក្នុងថ្ងៃធ្វើពិធីបុណ្យប្រទានតំណែង និងឋានន្តរសក្តិ “សម្តេចព្រះមហាឧបរាជ” តែម្តងទៅក្រាបទូល” ។ ព្រះមហាក្សត្រទ្រង់មានបន្ទូលថា “អស់លោក! តើមានយោបល់យ៉ាងណា ចំពោះរឿងនេះ? ខ្ញុំនឹងចាត់ការតាមអង្គប្រជុំ” ។ អង្គប្រជុំយល់ស្របទាំងអស់ ដោយអបអរសាទរយ៉ាងក្រៃលែង ។ ព្រះចៅក្រុងពារាណសី ស្តេចទ្រង់ត្រាស់ថ្លែងអំណរគុណអង្គប្រជុំថា “អស់លោក! ខ្ញុំត្រេកអរណាស់! អរគុណអស់លោកជាអនេក ព្រោះយោបល់អស់លោកស្របនឹងយោបល់របស់ខ្ញុំទាំងស្រុង, ៧ថ្ងៃទៀតយើងត្រូវធ្វើពិធីប្រទានតំណែងនិងអភិសេកព្រះរាជធីតារបស់ខ្ញុំ ដូចនេះ, សូមអស់លោកចាត់រៀបចំពិធីនេះឲ្យបានទៀងទាត់ និងឲ្យអ្នករាជការ-កម្មករក្នុងព្រះរាជាណាចក្រឈប់សម្រាក៣ថ្ងៃ ដើម្បីនឹងបានមករួបរួមក្នុងពិធីនេះផង ។

កាលព្រះពោធិសត្វ ទ្រង់បានទទួលការតែងតាំង ជាសម្តេចព្រះមហាឧបរាជ-ព្រះរជ្ជទាយាទនិងជាព្រះរាជសុណិសានៃព្រះចៅពារាណសីហើយ ទ្រង់បានសាងប្រាសាទមួយជូនមាតាបិតា នៅក្បែរប្រាសាទរបស់ព្រះអង្គ និងទ្រង់បញ្ជូនភោជនាហារ ទៅឲ្យមគ្គទេវយក្ស រាល់ៗថ្ងៃ ។ រាល់ៗថ្ងៃ ព្រះអង្គធ្លៀតយាងទៅសួរសុខទុក្ខប្រជារាស្ត្រ និងអ្នករាជការដែលនៅដាច់ស្រយាលឆ្ងាយៗពីរាជធានី ឬទីប្រជុំខេត្ត, ព្រះអង្គទ្រង់

ណែនាំពន្យល់ឲ្យចេះស្រឡាញ់គ្នា ចេះជួយធុរៈគ្នាទៅវិញទៅមក ចេះស្រឡាញ់ការហត្ថកម្ម ចេះស្រឡាញ់ផលប្រយោជន៍ជាតិ ចេះស្រឡាញ់ស្រែចំការ ។ល។ ថ្ងៃសីល ពេលព្រឹកទ្រង់ទទួលប្រជាជនដែលកើតទុក្ខមិនសុខចិត្តអំពីរឿងកាត់ក្តី ។ ព្រះអង្គទ្រង់វែកញែកកាត់ដោយយុត្តិធម៌ ហើយទ្រង់ទូន្មានឲ្យលះបង់អំពើលោភលន់ជាហេតុនាំឲ្យវិនាសផង ។ ពេលល្ងាច ទ្រង់សម្តែងធម៌ថ្វាយព្រះរាជា មន្ត្រី មហាជន និងមគ្គទេវយក្ខ ។ ទ្រង់បង្រៀនច្បាប់ និងអប់រំមន្ត្រីឲ្យចេះស្រឡាញ់យុត្តិធម៌ ចេះស្រឡាញ់រាស្ត្រ ចេះស្រឡាញ់ជាតិ ចេះស្រឡាញ់ផលប្រយោជន៍រាស្ត្រ និងចេះស្រឡាញ់អាជីវកម្មរបស់រាស្ត្រ ។ ដោយការដឹកនាំដ៏ឈ្លាសវៃ នៃព្រះពោធិសត្វ, ប្រជាពលរដ្ឋក្នុងប្រទេសមានការស្រុះស្រួលមូលមិត្តសាមគ្គីចងបាច់គ្នា ។ បើមានជនណាមួយមានធុរៈម្តង ៗ អ្នកផងតែងលើកគ្នាទៅជួយ រហូតដល់ការនោះបានសម្រេចជាស្ថាពរ ។ ប្រជាពលរដ្ឋក្នុងប្រទេសនេះ ឧស្សាហ៍ធ្វើការព្យាយាម និងប្រឆាំងចំពោះឧបសគ្គនានាដោយពុំមានចិត្តរាថយឡើយ ។ អ្វី ៗ ដែលគេចង់បានហើយ គេពុះពារឧបសគ្គគ្រប់ដំពូក យកជ័យជម្នះឲ្យខាងតែបាន ។ បើមានទំនាស់គ្នានិងគ្នា គេតែងតែពិភាក្សា ដោះស្រាយគ្នា គេមិនយកកំហឹងទល់កំហល់ទេ ។ ភោគផល ដែលកើតឡើងដោយការសាមគ្គី បានធ្វើឲ្យអ្នកស្រុកក្នុងប្រទេសទាំងមូល រស់នៅដោយសុខស្រួល ។

— ចប់ —

# ផ្នែកអក្សរសាស្ត្រ

## វចនានុក្រមសំស្ក្រឹត-ខ្មែរ

(៣)

*ព្រះមហា អាំង-ខាត់ រៀបរៀង*

អភិមទ៌ ពុ. កិរិយាកក្រេប ។

អភិមទ៌ន នបុ. កិរិយាសង្កត់សង្កិន កិរិយាបំផ្លាញ ។ គុ. ដែលកួលប៉ត្តបំផ្លាញ ។ -មទ៌ិន៑ គុ. ដែលបំផ្លិចបំផ្លាញ ។

អភិមឝ៌ ពុ. កិរិយាប៉ះពាល់ កិរិយាសេព ។ មឝ៌ក គុ. ដែលប៉ះពាល់ ។

អភិមឝ៌ន នបុ. កិរិយាបះ (ការបះធម្មតា) ។ គុ. ដែលបះ។ -មឝ៌ិន៑ គុ. ដូចគ្នា ។

អភិមឞ៌ ដូចអភិមឝ៌ ។

អភិមាន ពុ. អភិមានៈ គំនិត មត់ខ្លួនឯង ។ កិរិយាប្រអើត។

-វុត្តិ គុ. ដែលយកតែគំនិតខ្លួនឯង ។ គុណ-

[illegible] រូប ។ -[illegible] គុ. [illegible]

[illegible] ។

អភិមានិ គុ. កើតមានអភិមានៈ ។ -មានិតា ស្ត្រី.

ភាវនៃ . . មានអភិមានៈ ។

អភិមារុតបិ ប្រ.វ. ដោយប្រាណខ្ពស់ ។

អភិមុខ គុ. អភិមុខ កើតមានមុខឆ្ពោះ ដែលចំពោះមុខ

-តា ស្ត្រី. ភាវនៃកិរិយាមានមុខឆ្ពោះសេចក្ដី

អនុគ្រោះ ។

អភិមុបិ ប្រស្រឡះ ។

អភិមុខ ក្រិ.វិ. ចំពោះមុខមុនិ ។

អភិមុទិត គុ. ដែលជំរុញ ដែលពន្លះ។

អភិម្ឫជិ ធាតុ លុប ។

អភិម្ឫទុ ធាតុ [illegible] យាយី ។

អភិម្ឫគ ធាតុ [illegible] ។ -[illegible] គុ. [illegible]

ដែលបះពាល់ ដែលវាយ ។ -ឃាតជ គុ. ដែលកើតពីកិរិយាប៉ះពាល់ ដែលខុសច្បាប់ ។

អភិយជិ ធាតុ បូជាក្រៃលែង ជូនចំពោះ ធ្វើយជ្ញ ។

អភិយា ធាតុ ចូលទៅជិត ចូលកាន់ ចូលទៅគម្រាម ចូលលុក ។ –យាត គុ. ដែលចូលទៅចំពោះមុខ ដែលជួប ដែលដល់ ។

អភិយោ គុ. ដែលប្រុងប្រយ័ត្ន ។

អភិយាចិ ធាតុ អង្វរ ។

អភិយាចន នបុំ. កិរិយាអង្វរ កិរិយាសុំ ។

អភិយាតុ ការក. អ្នកវាយលុក ។

អភិយាន នបុំ. អភិយាន កិរិយាចូលលុក ។

អភិយាយិន គុ. ដែលចូលទៅជិត ដែលចូលលុក ។

អភិយុជិ ធាតុ ប្រកបក្រៃលែង ។ ចោទ វាយលុក ។ និយាយ ។ អញ្ជើញ ។ –យុត្ត គុ. ដែលវាយលុក ដែលចោទប្រកាន់ ដែលពិសោធ ។

អភិយុធ ធាតុ ច្បាំង ។

**អភិយោក្តព្យ** ដែលគប្បីប្តឹងក្តី ។

**អភិយោក្ត្ឫ** ការក. អ្នកវាយលុក អ្នកប្តឹង អ្នកចោទ សត្រូវ ។

**អភិយោគ** បុំ. អភិយោគ កិរិយាយកចិត្តទុកដាក់ ។ បដិបត្តិ ។ កិរិយាចូលវាយ ។ កិរិយាប្តឹងក្តី ។

**អភិយោគ្យ** ដែលគួរតស៊ូ ។

**អភិយោជ្យ** ដែលគួរច្បាំង ។

**អភិរក្ស៑** ធាតុ អភិរក្ស រក្សា ។ – រក្សិត គុ. ដែលរក្សា ។

**អភិរក្សណ** នបុំ. អភិរក្សណំ កិរិយារក្សា ។ – រក្សា ស្ត្រី. ដូចគ្នា ។

**អភិរក្សិត្ឫ** ការក. អ្នករក្សា អ្នកការពារ ។

**អភិរញ្ជ៑** ធាតុ រីករាយ, ស្រើបស្រាល ។ – រក្ត គុ. ដែលស្រើបស្រាល ។ – រញ្ជិត គុ. ដែលឡើងពណ៌ ។

**អភិរតិ** ស្ត្រី អភិរតិ កិរិយាត្រេកត្រអាល ។

(នៅមានត)

# វប្បធម៌ មន-ខ្មែរ

លោក ឌីកា - តាម រៀបរៀង

ហេតុដែលខ្ញុំយកវប្បធម៌ មន-ខ្មែរ មកសរសេរនេះ ព្រោះខ្ញុំយល់ឃើញថា ជាតិទាំងពីរនេះមានអារ្យធម៌ វប្បធម៌ច្រើនណាស់ ដែលដូចគ្នា ដូចការគោរព ការប្រតិបត្តិជាដើម ។ សូម្បីតែអក្សរ ក៏មានកិនភាគ ឬ ន័យថា មន-ខ្មែរ ដែរ ។ ដើម្បីឲ្យងាយយល់នូវវប្បធម៌ខ្លះ ៗ ដែលស្រដៀងគ្នា ខ្ញុំសូមជូននូវតែខ្លះដូចតទៅនេះ ។

## អត្ថន័យ

ដើម្បីឲ្យងាយយល់នូវន័យនៃពាក្យថា មន សូមលោកអ្នកអានសង្កេតនូវន័យនៃពាក្យនេះឲ្យហ្មត់ចត់ ដូចតទៅនេះ ៖

តាមបរិភាសាបាលី ( Pali terminology ) ថា ពីដើមគេហៅមនថា រាមញ្ញៈ ឬ រាមញ្ញទេស (Ramannadesa) តែពួកកុលសម្ពន្ធទាំងគ្នាហៅជនពួកនេះថា រ្មន (Rman) បានជាក្លាយមកជា មន ដូច្នេះ ។ ពាក្យថា មន នេះជាឈ្មោះនៃជនមួយពួក ដែលពួកកុលសម្ពន្ធហៅថា រ្មន ។

## ប្រជាជាតិមន និង ឥភាវតារ

The Môn people and Their History

ប្រជាជាតិដែលគេហៅថា មន ច្រើនគ្នាណាស់ដែលយល់ថា ជា

ប្រទេសភូមា ឬ ជាប្រជាកស្រ្តនៃប្រទេសភូមា ។ ឯពួកអឺរ៉ុបវិញ គេតែងតែនឹកថា មន នេះគឺជា ជាតិតាឡាំង (Talaing)

ជាតិមនសព្វថ្ងៃនេះ ពិតមែនតែមានជាតិនឹងគេដែរ តែមិនបាន នៅតែមួយកន្លែង ឬមានសិទ្ធិដូចសម័យដែលមនមានឥស្សរភាពពេញបរិបូណ៌ទេ បើនិយាយឲ្យងាយចូលចិត្តទៅ មន សម័យនេះដូចគ្នានឹង ចាម នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃ តែចាមរត់មកជ្រកនៅប្រទេសខ្មែរ ឯ មននៅក្នុងប្រទេសរបស់ឯង តែនៅត្រង់នេះបន្តិច ត្រង់នោះបន្តិច ។ ម្ចាស់ស្រុក គឺមននេះ នៅដោយដុំៗ ក្នុងប្រទេសភូមា ។ ជាតិមន ដែលមាន ច្រើននៅក្នុងប្រទេសភូមា ច្រើនតែនៅតាមដូរឆ្នេរទាំងសងខាង ក្បែរ មាត់ទន្លេ (Salween) ក្បែរបេគូ ( Pegu ) ។

នៅឆ្នាំ ១៩១១ ការិយាល័យជំរឿនប្រជាកស្រ្តនៃប្រទេសភូមា បាន ធ្វើនូវការជំរឿនប្រជាកស្រ្តទៅ ឃើញមានជាតិមន នៅសល់ត្រឹមតែ ៣២០.៦២៩ នាក់ តែបណ្ដាមនទាំងនេះ មានតែចំនួន ១៧៩.៤៤៣ នាក់ទេ ដែលអាចនិយាយភាសាមនបាន ។

ជាតិមននៅក្នុងប្រទេសភូមាសព្វថ្ងៃ នៅរាយតាមតែកន្លែងដែលខ្លួន ធ្លាប់នៅ ឬតាមតែរាជការតម្រូវឲ្យនៅ ។ ទីដំបន់ដែលមានជាតិមននៅ ច្រើន ក្នុងប្រទេសភូមានិ៍ នៅដំបន់តេណាសេរ៉ិម (Tenasserim) មាន ចំនួនត្រឹមតែ ១៣៥.១២៧ នាក់ នៅដំបន់អាមហឹរ្ស (Amherst ចំនួន

១៣៩.៩៧០ នាក់ នៅដំបន់ថាទន (Thaton ចំនួន ៣៤.៨០៥ នាក់ ឯដំបន់ពេគូ (Pegu វិញមានចំនួនតែ ១៩៦០ នាក់ ។ ក្រៅពីដំបន់ទាំងនេះ ជាតិមនមានចំនួនតិចណាស់ហើយ ស្ទើរតែរកស់គាល់ថាជាជាតិមនមិនបានផង ព្រោះពួកនេះមិនបេះភាសាមន មិនមានទំនៀមទំលាប់មន ។

សម័យដើម ដំបន់នៅប្រទេសភូមា ដែលមានជាតិមននៅកាន់កាប់នៅឡើយ ភាសាមនផ្សាយអំណាចរាតទៅទៅស្ទើរតែគ្រប់ដំបន់ ដោយឆាប់រហ័សណាស់ ។ នៅដំបន់ខាងជើង ភាសាមនបានផ្សាយអំណាចទៅដល់ប្រូម (Prome) ឯខាងត្បូងវិញ ក៏ជាតិមនទំផ្សាយរាតទីអំណាចរបស់ខ្លួនណាស់ដែរ តែមកដល់ក្រោយ ជាតិមនត្រូវថយអំណាចហើយចំនួនជនជាតិមន ក៏ថយចំនួនទៅតាមលំដាប់ដែរ ពីព្រោះជាតិភូមាចូលមកកតត្បាតប្រទេសមន ហើយភូមាបានតាំងអំណាចសឹប់នៅលើពួកមនបានហើយ ទើបបង្កើតជាអាណាចក្រឡើងហៅថាអាណាចក្រភូមានៅបាគន (Bagan) ហើយប្រជាជាតិភូមាទៅតាំងទីនៅតាវ៉យ (Tavoy) និងនៅតេណាសេរ្សរិមខាងត្បូង (South Tenasserim) ហេតុដូចនេះហើយ ដែលធ្វើឲ្យជាតិមននេះ បេះតែថយចំនួនទៅជាដរាប ។

កជាណាចក្រមននៅតាំងបានតែត្រឹម គ.ស. ១៥៤០ ព្រោះតែមានការកតត្បាតរបស់វង្សក្សត្រភូមាមកពីតូងគូ (Taungu) ហើយក្រោយមកទៀតបានទៅពួកភូមាមកគ្រួតត្រាភាគខាងលើ ។ ព្រឹត្តិការណ៍នេះហើយ

ដែលជាហេតុនាំឲ្យជាតិមន បាត់បង់ជាតិរបស់ខ្លួន ឬថយចំនួនជាតិរបស់ខ្លួនជាលំដាប់រាល់ថ្ងៃ ។

### អំណាចភូមាលើជាតិមន និង ភាសា

ប្រជាជាតិណាក៏ដោយ ប្រទេសណាក៏ដោយ ឲ្យតែបាត់បង់ឯករាជ្យជាតិហើយ ភាសាក៏បាត់បង់អាប់ឱនទៅដែរ ដូចមានភាសិតថា "ភាសា បាត់ ជាតិរលាយ" ។

លទ្ធផលដែលនាំឲ្យភាសាមននេះ បាត់បង់ថយឥទ្ធិពលជាលំដាប់នោះមកពីសន្តិវង្សអាឡោមប្រា (Alompra Dynasty) នៅសតវត្សទី១៧ ដល់សតវត្សទី ១៩ បានប្រើអំណាចសង្កត់សង្កិន ជាតិមនពេក រកតែគ្នាងើបមុខមាត់មិនបាន ។ សម័យដែលភូមាមកគ្រួតគ្រាមន កន្លែងណាដែលមានជាតិមននៅ ច្រើននិយាយភាសាមនច្រើន កន្លែងនោះរាជការភូមារកមធ្យោបាយ ដើម្បីធ្វើឲ្យជាតិមនមានចំនួនតិចឬកុំឲ្យនៅមួយកន្លែងមានគ្នាច្រើន ។ ការធ្វើដូច្នេះ ដើម្បីកុំឲ្យពួកមនទាក់ទងគ្នា និងកុំឲ្យនិយាយភាសាមនរកគ្នា ។ ការបំបែកគ្នាឲ្យនៅដាច់ដោយឡែកដូច្នេះជាហេតុនាំឲ្យភាសាមនចុះថយ រកមនុស្សនិយាយជាមួយគ្មានតែភាសាថយហើយ ពួកភូមាយល់ថា ជាតិមននឹងមានចំនួនថយដែរ ។ ភាសាមនដែលចុះខ្សោយលែងប្រើប្រាស់នៅ គ.ស. ១៧៥៧ មាននិយាយទាក់ទងគ្នាបន្តិចបន្តួច ហើយមកពី គ.ស. ១៨១៦ ដល់ ១៨៥២ នៅ

បេគូ (Pegu) ក៏មិនមានច្បាប់ណាមួយជួយការពារកាសាមនឲ្យមាននិយាយ ឬប្រើប្រាស់ដែរ ។ សូម្បីតែនៅគេណាសេរីម ដែលជាកន្លែងធ្លាប់មានជាតិមននៅច្រើនស្រាប់ ហើយមននៅមានអំណាចខ្លះផង ក៏មិនមានច្បាប់ណាមួយជួយគាំពារកាសាមនឡើយ ដល់មកសម័យដែលវេង្គកិបាលអង់គ្លេស ចូលមកគ្រប់គ្រងប្រទេសភូមា ក៏អង់គ្លេសមិនអើពើនឹងជួយការពារឲ្យជាតិមនមានការប្រើកាសាមនដែរ ។

ហេតុដែលខ្ញុំយកអាណាចក្រទ្វារាវតីមកនិយាយនេះ ព្រោះខ្ញុំចង់បង្ហាញឲ្យឃើញនូវវប្បធម៌មន-ខ្មែរដែលដូចគ្នាខ្លះ ។ ខ្មែរយើងពីដើមធ្លាប់ផ្សាយអាណាចក្រទៅដល់គ្នាទីងមន ដូចអាណាចក្រទ្វារាវតី លពបុរី សុខោទៃ អាណាចក្រដែលខ្មែរធ្លាប់គ្រប់គ្រងមកជាច្រើនឆ្នាំ ។

## អាណាចក្រទ្វារាវតី

### ព.ស. ៨៦០ ដល់ ១១៥០

តាមសេចក្តីកត់ហេតុរបស់ចិនថា មានអាណាចក្រមួយឈ្មោះថា ទ្វារាវតី នៅក្នុងវាលស្រែកេត្រ គឺភូមា សៀមថៃ និងឥសាណបុរី ខ្មែរ ។ អាណាចក្រនេះប្រហែលជាទីរួមខេត្រ គឺមណ្ឌលក្រុងទេព អាយុធ្យា នគរជយស្រី រាជបុរី នគរសួគ៌ ពិណ្ណុលោកនិងប្រាចិណ ជាអាណាខេត្ត ។ និយាយពីអាយុធ្យា និងបាងកកវិញ ក្រុងទាំងពីរនេះ អយុធ្យាកើតមានពី

ឆ្នាំ ១៧៨១(១) ។ អាណាចក្រទ្វារវតី ពីដើមជារបស់ លវោ (លាវ) តែមិនមែនលាវនៅលួងប្រាបាង ឬវៀងចាន់ទេ ។ តែវេលាក្រោយមក នៅ ព.ស. ១៥០០ ខ្មែរកម្រាបលវោបាន ហើយក៏ចូលទៅនៅគ្រប់គ្រងអស់កាលជាយូរ តែការគ្រប់គ្រងនៅសម័យនោះ ជាប្រទេសកជ ។ សម័យដែលខ្មែរនៅគ្រប់គ្រងទឹកដណាទី នៅលពបុរី ឬជួនកាលនៅអាយុធ្យា តែច្រើននៅលពបុរី ព្រោះលពបុរី ជាទីក្រុងចាស់យូរមកហើយ ឯក្រុងអាយុធ្យានេះ ពីដើមក្នុងសម័យលវោគ្រប់គ្រងមិនមានឈ្មោះទេ ទើបមាននៅពេលដែលខ្មែរចូលទៅនៅគ្រប់គ្រង ។

នៅលពបុរី គេឃើញមានសិលាចារឹកមួយ ដែលជាភាសាមន ។ នៅសិលាចារឹកនោះ មាននិយាយថា ជាតិមនបានមកនៅទីនេះ ។ អ្នកដែលបានមកតាំងទីនៅ២កន្លែងនោះគឺមន ដែលចុះមកពីលវោ មានព្រះនាងចាមទេវីជាមេ ។

ដល់ខ្មែរចូលទៅគ្រប់គ្រង មានធ្វើថ្នល់កាត់គ្នាទៅវិញទៅមករវាងក្រុងយសោធរបុរី និង លពបុរី ។

## ពង្សាវតារលពបុរី

ដើម្បីឲ្យងាយយល់ នូវវប្បធម៌មន-ខ្មែរ និងការទាក់ទងរវាងមននិងខ្មែរខ្ញុំសូមនិយាយយ៉ាងខ្លីពីអាណាចក្រលពបុរី សម័យដែលប្រទេសកម្ពុជា

---

១.២-Histoire Ancienne des Etats Hindouisés, par G. Coedès, page 94.

នៅក្នុងមហាអំណាច ។ នៅសម័យប្រមាណ ព.ស. ១៥០០ មានសិលាចារឹកខ្មែរជាដំបូង នៅក្រុងលពៅដែលមានព្រះនាមនៃមហាក្សត្រខ្មែរប្រោកដនៅសិលាចារឹកនោះផង គឺព្រះបាទព្រះសុរ្យវរ្ម័នទី ១ ។ ក្រៅពីសិលាចារឹកនេះ នៅមានវត្ថុដទៃទៀតជាកស្តុតាងដូចជាការរចនាជាដើមដែលខ្ញុំនឹងនិយាយទៅខាងក្រោយ ។ ការទាំងនេះហើយ ដែលនាំឲ្យយើងដឹងច្បាស់ថា ក្រុងលពៅ ឬលពបុរី ធ្លាប់ជារាជធានីរបស់ខ្មែរ ជាក្រុងដែលខ្មែរធ្លាប់គ្រប់គ្រងត្រួតត្រាអស់កាលជាយូរឆ្នាំ ។

ការដែលថា ខ្មែរនៅត្រួតត្រាក្រុងលពៅ តាមសិលាចារឹកខ្មែរនេះ ឃើញថា នៅមិនទាន់អស់ចិត្តទេ តែបើសិនជាសង្កេតតាមឯកសារបរទេស ដូចជាឯកសារភាសាលាវជាដើម ឬភាសាបាលី ក៏មាននិយាយដូចតែឯកសារខ្មែរដែរ ។ ឯកសារលាវ នៅឈៀងម៉ៃ ដំណាលថា ប្រមាណ ព.ស. ១៥៥០-១៦០០ ក្សត្រគ្រប់គ្រងក្រុងហរិបុញ្ជយ ព្រះនាមត្រាពក ឬអត្រាពក បានធ្វើសឹកនឹងស្តេចដែលជាអ្នកនៅគ្រប់គ្រង ក្រុងលពៅព្រះនាមថា ឧច្ឆិតចក្រវត្តិ ។ ខណៈនោះកំពុងតែធ្វើសឹកនឹងគ្នា មានក្សត្រដែលគ្រប់គ្រងនគរស្រីធម្មរាជ បានចូលមកវាយក្រុងលពៅបាន ។ ព្រះរាជឱរសរបស់ក្សត្រនគរស្រីធម្មរាជ បានឡើងគ្រប់គ្រងរាជសម្បត្តិ ហើយទើបតាំងព្រះវង្សថ្មី ។ ព្រះរាជឱរសនោះ គឺព្រះបាទសុរ្យវរ្ម័នទី ១ ។ ព្រះរាជអង្គនេះ កាលបានឡើង សោយរាជប្រទេសកម្ពុជាហើយ ទ្រង់បានរួម

យកមណ្ឌលដែលព្រះបិតាវាយបាន ឲ្យចូលមកជាអាណាចក្រកម្ពុជា ។

ព្រះបាទសុរ្យវរ្ម័នទី ១ ដែលស្តេចយាងមកពីប្រទេសស្រីធម្មរាជ ដែលជាប្រទេសកាប់កាន់ព្រះពុទ្ធសាសនា ព្រះអង្គបានជួយទំនុកបំរុងព្រះពុទ្ធសាសនា ដល់ព្រះអង្គសោយទីវង្គតទៅ បានទទួលព្រះមរណៈបច្ឆានាមថា ព្រះនិព្វានបទ ។

## ទំនៀមបូជាសពរបស់ពួកមន

ទំនៀមទម្លាប់របស់មនជាច្រើន ដែលមានការគោរព ឬប្រព្រឹត្តដូចគ្នាតែការយកទំនៀមទម្លាប់ទាំងអស់មកអធិប្បាយ ឃើញថាជាហេតុនាំឲ្យអស់ពេល តែពេលនេះ ខ្ញុំយកតែការបូជាសពរបស់មនដែលឃើញថាដូចគ្នានឹងខ្មែរជាច្រើន គឺៈ ។

## ១- ការលើកសពចំអាសទឹក

ការលើកសពចំអាសទឹក តាមទំនៀមរបស់មន ឃើញមានប្លែកពីខ្មែរសព្វថ្ងៃ មនពេលលើកយកសពមកចំអាសទឹក ត្រូវមានមនុស្ស ៧ នាក់ ។ មនុស្សទាំង ៧ នាក់ នេះត្រូវកើតខុសថ្ងៃគ្នា ។ ពេលចូលទៅកន្លែងតម្កល់សពដែលត្រូវយកសពមកចំអាសទឹក គេត្រូវឲ្យមនុស្សដែលកើតនៅថ្ងៃអាទិត្យទៅមុន ហើយទើបអ្នកដែលកើតនៅថ្ងៃចន្ទអង្គារ ជាបន្តបន្ទាប់គ្នារហូត ដល់អ្នកដែលកើតថ្ងៃសៅរ៍ចូលទៅ បន្តបន្ទាប់គ្នា ។ កាលបើលើកសពចំអាសទឹករួចហើយ ពេលចេញមកវិញ ត្រូវឈរជាជួរសិន

មិនមែនម្នាក់ស្រោចទឹកលើសពហើយចេញមកទេ ត្រូវចេញមកបន្តបន្ទាប់គ្នាដែរ តែត្រូវអ្នកដែលកើតថ្ងៃសៅរ៍ចេញមកមុន ហើយសឹមអ្នកកើតថ្ងៃសុក្រ ព្រហស្បតិ៍ រហូតដល់អ្នកកើតថ្ងៃអាទិត្យចេញក្រោយគេ ។

ចំណែកទឹកដែលត្រូវយកទៅចំអាសសពនោះ ត្រូវដាំឲ្យពុះ ឬឲ្យក្តៅសិនហើយតម្កល់លើជើងក្រាន ដែលតម្កល់ថ្ម ៣ ដុំ ដែលជានិមិត្តរូបនៃភូមិទាំង ៣ គឺកាមាវចរភូមិ រូបាវចរភូមិ និងអរូបាវចរភូមិ ។

## ២ – ការបង់លុយក្នុងមាត់នៃសព

លុះចំអាសទឹករួចហើយ គេតែងបង់លុយទៅក្នុងមាត់នៃសព ។ ហេតុដូចម្តេចបានជាចាំបង់លុយទៅក្នុងមាត់នៃសព : តាមទំនៀមមនយល់ថា ការស្លាប់ទៅកាន់ឋានខាងមុខ ត្រូវឲ្យមានទ្រព្យសម្បត្តិខ្លះយកទៅជាមួយផង បើពុំនោះទេត្រូវឲ្យមានលុយកាក់ខ្លះ គ្រាន់ចាយវាយទិញរបស់ដែលត្រូវការ ។

ចំណែកខាងខ្មែរ- តាមឯកសាររបស់លោក ប៊ូ ប៊ូ ថា ការបង់លុយទៅក្នុងមាត់សព ដោយមានរឿងដូចតទៅនេះ :

មានប្តីប្រពន្ធពីរនាក់ ស្រឡាញ់គ្នាណាស់ មានមាសប្រមាណជា ១ បាទ ។ ប្តីប្រពន្ធបានផ្តាំគ្នាទៅវិញទៅមកថា បើនរណាស្លាប់ទៅសូមឲ្យយកមាសបង់ទៅក្នុងមាត់ផង ។ ស្រាប់តែក្រោយមក ប្តីស្លាប់មុន ប្រពន្ធក៏យក

មាសនោះទៅបង់ក្នុងមាត់ប្ដីតាមបណ្ដាំ ។ លុះបូជាសពប្ដីរួច ឃើញមាសនៅសល់ប្រហែល ៣ ស្លឹង ។

ថ្ងៃក្រោយមក ព្រះរាជាមានព្រះរាជបញ្ជា ឲ្យរៃមាសម្នាក់ ១ បាទ តែអ្នកមេម៉ាយនោះ មានមាសត្រឹមតែ ៣ ស្លឹង ទើបចូលទៅក្រាបថ្វាយមាសដែលសល់ពីភ្លើង ព្រះរាជាទ្រង់ព្រះសង្កេត ទើបឈប់ឲ្យរៃមាសទៅៗ

## ៣-ការរំកិលសព

ថ្ងៃរំកិលសពចេញពីផ្ទះ តាមទំនៀមមក គេមិនយក ឬរំកិលសពចេញតាមទ្វារដែលចេញចូលសព្វថ្ងៃទេ ហើយមិនឲ្យចុះតាមជណ្ដើរដែលមនុស្ស ឬម្ចាស់ផ្ទះចុះឡើងទេ ។ គេត្រូវទំលាយជញ្ជាំង ហើយត្រូវធ្វើជណ្ដើរផ្សេងមួយទៀត ទុកសម្រាប់តែរំកិលសពចុះប៉ុណ្ណោះ ។ សពត្រូវសែងចេញយកទៅបូជា ត្រូវសែងយកក្បាលទៅមុន ព្រោះកាលដែលព្រះសមណគោតម បានរៀបចំពិធីឈាបនកិច្ចព្រះបិតារបស់ព្រះអង្គ ក៏ហែព្រះសពយកព្រះកេសទៅមុនដែរ ។ តែសម័យមុននេះ គេសែងសពយកជើងទៅមុន ។

លុះទៅដល់ឈាបនដ្ឋានហើយ គេត្រូវហែប្រទក្សិណទីបូជាសពឬឈាបនដ្ឋាន ៣ ជុំ នេះជានិមិត្តរូបនៃការកើត ឈឺ ស្លាប់ ។ តាមឯកសាររបស់លោក ប៉ូ ប៉ុ ហា បុគ្គលដែលមានកិលេសច្រើន តែងតែរវល់

ចាស់ ឈឺ ស្លាប់ កើតនៅក្នុងភពវដ្តសង្សារ ហេតុដូច្នេះហើយបានជាគេហែប្រទក្សិណឈាបនដ្ឋាន ៣ ជុំដែរ ។

តាមទំនៀម នៅក្នុងពិធីបូជាសពនៅមានច្រើនណាស់ ដែលមានពិធីប្រហាក់ប្រហែលនឹងខ្មែរ តែពេលនេះ ខ្ញុំយកតែពិធី ៣ យ៉ាងនេះមកជូនជាឧទាហរណ៍ ដើម្បីឲ្យឃើញថា ពួកមនមានទំនៀមច្រើនដែលដូចនឹងខ្មែរ ។ ទំនៀមបូជាសពពួកមន មិនមែនដូចគ្នាតែទាំងអស់ទេ មានកន្លែងខ្លះ ក៏ខុសដែរ ។ ដូចលោក រ.ហាលីដេថា ទំនៀមក្នុងការបូជាសពមនមានពិធីខុសគ្នាផ្សេងៗ ខ្លះ ដូចពួកមនខ្លះ តែមានអាយុឬមានសភាពនិងធ្ងើមរណាកាល គេតែងធ្វើផ្ទះ ឬពេងជាប់ដោយខ្សែកសម្រាប់តែឲ្យមនុស្ស គេមិនចង់ឲ្យមនុស្សស្លាប់នៅក្នុងផ្ទះជាមួយទេ ព្រោះគេខ្លាចក្រែងចង្រៃ ។

## បែបរចនា

ការរចនារបស់មន-ខ្មែរមិនដូចគ្នាប៉ះប៉ិនទេ គេនៅសង្កេតបានថា នេះជារបស់ខ្មែរ នេះជារបស់មន ដូចការកសាងព្រះពុទ្ធរូបជាដើម ។ ការកសាងព្រះពុទ្ធរូបតាមបែបខ្មែរ និងមន គ្រាន់តែក្រឡេកមើលភ្លាមគេអាចសំគាល់បានថា នេះជារបស់មន នេះជារបស់ខ្មែរ ។

មុនពុទ្ធសករាជ ៩៦៣ ដល់ ១៤៦៣ នៅប្រទេសសៀម គេឃើញ

ក្បាច់រចនា ប៉ុន្តែមនច្រើនជាង មនដែលយកសាងព្រះពុទ្ធរូបនេះ សុទ្ធតែពួកមនមកពីប្រទេសភូមាខាងក្រោម ។ ប៉ុន្តែរចនារបស់មននេះ ជាក្បាច់ដែលមានលំនាំតាមបែបរចនារបស់ហិណ្ឌូ តាំងពីពុទ្ធសករាជ ៨៤៣ ដល់ ៩៤៣ ។ ក្បាច់រចនារបស់មននេះហើយ ដែលគេស្គាល់បាននូវវង្សនៃស្តេចមន ក្នុងសម័យគុប្តៈ ឥណ្ឌាប៉ែកខាងជើង ។

លុះមកដល់ពុទ្ធសករាជ ១៥៤៣ ដល់ ១៧៩៣ រចនារបស់ខ្មែរក៏ចូលទៅនៅប្រជែងជាមួយរចនាមន ព្រោះតាំងពីពុទ្ធសករាជ ១៥៤៣ ស្រុកសៀមកណ្តាល នៅក្នុងអំណាចស្តេចខ្មែរគ្រប់គ្រង ដូច្នេះហើយ បានជាគេឃើញមានរចនាខ្មែរនិងមននៅលាយឡំគ្នា ។

តែបែបរចនាទាំងពីរនេះ នៅឃើញផ្សេងគ្នា ។ បែបប្ញកិទភាគនៃការរចនារបស់មន-ខ្មែរ ដូចការកសាងព្រះពុទ្ធរូបជាដើម ព្រះពុទ្ធរូបខ្មែរមានទ្រង់ទ្រាយជារូបបុរស ឃើញស្តែងជាងព្រះពុទ្ធរូបបែបមន ។

អាស្រ័យហេតុនេះហើយ បានជាគេអាចសន្និដ្ឋានបានថា ខ្មែរ-មនមានវប្បធម៌ច្រើនដូចគ្នា មិនមែនតែខាងរចនាទេ ដែលនៅលាយឡំគ្នា សូម្បីតែខាងភាសា និងអក្សរ ក៏ឃើញនៅលាយឡំគ្នាដែរ ។ គេឃើញមានសិលាចារឹករបស់ខ្មែរជាច្រើនដែលនៅលពបុរី ជាភាសាខ្មែរខ្លះ មានលាយភាសាមនខ្លះ ។ សូមអានទៅខាងក្រោយ លោកអ្នកនឹងឃើញ សិលាចារឹករបស់ខ្មែរនៅលពបុរី :

# សិលាចារឹកខ្មែរនៅលពបុរី

សិលាចារឹកនេះហើយ ជាស្នាដៃមួយសរឲ្យឃើញថា អារ្យធម៌របស់ខ្មែរនៅតែពាសពេញប្រទេសសៀម ។ សិលាចារឹកខាងក្រោមនេះ ជាសិលាចារិករបស់ខ្មែរនៅលពបុរី :



សរសេរជាខ្មែរសព្វថ្ងៃ :

១- រៅបុណ្យជុស្នាចយុគ្រោះ

២- ដេកមុនជុនតក្យាកល

៣- ត្នាបរិតយមោញះ

៤- ខះបបុណ្យតាបឥន្ទ

៥- ដេកមុនជុនតក្យាក

៦- វុទ្រក្យសះបិជ្ជោ

៧- វបិបុះ

សេចក្តីប្រែសំរួល: ១ នេះគឺជាបុណ្យរបស់គ្រហស្ថឈ្មោះ ផុស្ធយុ ។

២- មានសទ្ធា បរិចាគខ្ញុំគំដរឲ្យបំរើវត្តអាកម ។ ៣- សទ្ធាចរិត ជាឈ្មោះអ្នកធ្វើអំណោយ ៤- តាប ឥន្ទ បានធ្វើបញ្ញកម្ម ៥- ខ្ញុំគំដរដែល បានថ្វាយទៅវត្តអាកម ៦- ឈ្មោះថាវត្តទិរក្សស់ះ ទិង សិ ៧- គ្របី ។

សិលាចារឹកនៅលពបុរី ដែលយកមកធ្វើជាឧទាហរណ៍នេះ ជាសិលាចារឹករបស់មន-ខ្មែរ ។ ម៉េចបានជាហៅថារបស់មន ខ្មែរ:

បញ្ហានេះ ខ្ញុំដែលជាអ្នកសរសេរអត្ថបទនេះ គឺមិនដឹងជាភាសាមន ដូចម្តេចដែរ តែការអានតាមឯកសាររបស់អ្នកប្រាជ្ញចេះដឹងធំៗ ដូចលោក ហ្ស.សឺដេស G. Coedès ជាដើមឃើញថាសិលាចារឹកនេះ ជាភាសាមន មានលាយភាសាខ្មែរលោកហ្ស.សឺដេស បានយោងប្រាប់ទៅតាមឯកសារ របស់លោក M. Duroiselle ជាអគ្គិរក្សបុរាណវត្ថុនៅប្រទេសភូមា ។

សិលាចារឹកនេះមានអត្ថបទយ៉ាងសង្ខេប ដែលមានអក្សរមានលំនាំ ជាអក្សរខ្មែរ ។ បែបអក្សរដែលចារនៅ លើសិលាចារឹកនេះ មានលំនាំ ជាអក្សរខ្មែរ នៅសតវត្សរ៍ ៦ ឬ ៧ ។ បើបែរទៅមើលសិលាចារឹកជា ភាសាបាលីវិញនៅស្រុកសៀម ដូចជាសិលាចារឹកនៅព្រះបឋមស្ធូបជា ដើម ។ សិលាចារឹកនៅលពបុរីនេះ មានអត្ថបទ ជាភាសាបុរាណ ហើយវេលច់ខ្ះ ។ ។

សូមអានអត្ថបទនៅទំព័រ ៩០៩ ហើយសូមប្រៀបធៀបនឹងសិលាចារឹកខ្មែរដទៃទៀត ។

## ការប្រៀបធៀបភាសា

ដើម្បីឲ្យឃើញថាភាសាមន និង ខ្មែរមានអំបូរមកជាមួយគ្នា សូមលោកអ្នកអានសង្កេតពិនិត្យ នូវភាសាទាំងពីរនេះ និងភាសាកុល-សម្ពន្ធនៅភ្នំខ្លះ ៗ បានជាខ្ញុំយកភាសាអ្នកនៅភ្នំមកនិយាយផង ព្រោះខ្ញុំយល់ឃើញថា ពួកអ្នកនៅភ្នំមានភាសានិយាយមិនទាន់បែរទៅរកភាសានេះ ឬ ភាសានោះនៅឡើយ ៖

| ខ្មែរ | មន(១) | ស្ទៀង |
|---|---|---|
| ត្រី | កា | កា |
| ភោង | កុន | |
| កូន | កន | កុន |
| ចៅ | ចារ៍ | សៅ |
| ជើង | ជេង | ជឹង |
| ដៃ | តាយ | សុិស |
| ដី | តី | តេះ |
| ថ្ម | ថ្ម | តឹះមៅ |

១- សូមអភ័យទោស បើការអានភាសាមន និង ស្ទៀង មិនបានត្រឹមត្រូវតាមសូរសាស្ត្រ ។

| | | |
|---|---|---|
| ល្ពៅ | គ្ពិ | |
| ឆ្នាំ | ស្នាំ | សឹណាំ |
| ទឹ | ទក | ទក |
| ប្រមុះ | មុះ | ក្រេមុះ |
| ថ្មី | កៈមី | មុី |
| បុល | រើស | រៀស |
| រុយ | រូយ | រូយ |
| សក់ | សុក | សុក |

## ការប្រៀបធៀបភាសា ខ្មែរ-មន ១:

| ខ្មែរ | មន | ខ្មែរ | មន |
|---|---|---|---|
| សេះ | ធេះ | ដើម | គេម |
| អុស | អស់ | ស៊ិបាយ | ជាក់ប៊ឺង |
| កូន | កន | កូនប្រុស | កនប្រុស |
| ដក់ថ្នាំ | ជាក់កៈអ៊ុ | កូនស្រី | កនស្រី |
| បាយ | ប៊ឺង | វត្ត | ពោង |
| វត្តឧណ្ណាលោម | ឧណ្ណាលោមពោង | អាចម៍ | អ៊ិក |
| ដៃ | តៃ | ប្អូន | ប៉ាន |
| ក្ដយ | ក្ទិ | ស្រូវ | ស្រូ |

# ការរាប់ចំនួន

ដើម្បីឲ្យងាយយល់ក្នុងការរកទ សូមប្រៀបធៀបតាមអក្សរ

| ខ្មែរ | មន | ស្ទៀង | ព្រាក | |
|---|---|---|---|---|
| Muoy | Moy | Mui | Muoi | 1 |
| Pir | | Bar | Bar | 2 |
| Bei | Pi | Pe | Pe | 3 |
| Buon | Pan | Puon | Poun | 4 |
| Pram | | Pram podam | Pram | 5 |
| Pram muoy | | Prau | Prau | 6 |
| Pram pir | Tapah | Poh | Pah | 7 |
| Pram bei | D-cam | P'ham | Pham | 8 |
| Pram buon | | Sienh | Chin | 9 |
| Dap | | djemat | djet | 10 |

ការប្រៀបធៀបនូវភាសាទាំង ៤ បែបនេះ ឃើញមានភាសាខ្លះ រាប់ដូចគ្នា ខ្លះស្រដៀងគ្នា ៗ

ក្រៅពីភាសាទាំង ៤ នេះ សូមលើកយកភាសាអ្នកនៅក្នុងខ្លះមក ប្រៀបធៀប ដើម្បីឲ្យឃើញច្បាស់ នូវភាសាទាំងនោះ តែពេលនេះ សូមយកតែការរាប់ចំនួនមកជូន ដូចតទៅនេះ

| ជ្រាយ | រដែ | ចាម | |
|---|---|---|---|
| Sa | Sa | Sa | 1 |
| Duà | Dòa | Dua | 2 |
| Klao | Tlao | Klau | 3 |
| [illegible] | Pa | Pak | 4 |
| Roma | Ema | Limo | 5 |
| Nam | Nam | Nam | 6 |
| Tojuh | Kjuh | Tijuh | 7 |
| Sopan | Fpan | Dalapan | 8 |
| Duaropan | Doapen | Salapan | 9 |
| Pluh | Pluh | Pluh | 10 |

ទោះបីមានការកែនទម្រង់ត្រូវតាមភាសាដើមដែលភាសានីមួយ ៗ

សូមមេត្តាជួយការតាមដែលលោកអ្នកធ្លាប់បានដឹងផង ៗ

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ឆ្ន - ភាគ ៨

ប្រែ-រៀបរៀង

(៣)

| | |
|---|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ | អ្នករាងវៃឆ្លាសបើបានអាន |
| នឹងចេះឧបាយកលចំណាន | ទាំងមានសន្តានស្នេហាជាតិ |

យូរ-អ៊ុន

ម៉ាតាយឃើញ បេងហេក-បេងហ៊ុរ ក៏យកដាវចង្អុលមុខហើយថា បើយើងចាប់ខ្លួនបានម្តងទៀត មុខជាមិនលែងទេ ៗ បេងហេក-បេងហ៊ុរ មិនឆ្លើយតបថាម្តេចសោះ ចេះតែឱនដាក់មុខហើយដើរទៅ, លុះដើរទៅដល់បន្ទាយវៀង ទើបចូលទៅ ទទួលក្រឡេកឃើញជូឡុង និងទាហាន នៅពេញក្នុងបន្ទាយនោះ ៗ ជូឡុង ក៏ស្រែកឲ្យបេងហេក-បេងហ៊ុរថា ចៅហ្វាយយើងមានគុណលើអ្នកឯងច្រើនណាស់ ហេតុម្តេច អ្នកឯងមិនដឹងគុណសោះ?, បេងហេក-បេងហ៊ុរមិនឆ្លើយតបសោះ ក៏ឱនដាក់មុខដើរប្រញាប់ទៅ, លុះទៅដល់ប្រហាបច្រកភ្នំ ឃើញអ៊ុយអៀនមានទាហានទៅស្កាត់ពីមុខ ក៏ទឹកភ័យណាស់, អ៊ុយអៀនស្រែកថា ឥឡូវយើងបាន ធ្លងមកត្រើយខាងនេះ ចូលក្នុងដែនរបស់ខ្លួនហើយ ខ្លួននៅត្រូវស្នើងទៅ

ដល់ណាទៀតទើបចង់ច្បាំងនឹងយើង  បើយើងចាប់បានខ្លួនម្តងទៀតនឹងកាប់ចញ្ច្រាំជា ១០ ៗ កំណាត់ ។ បេងហោក-បេងហ៊ុវមិនឆ្លើយតបសោះ ឱនជាក់មុខដើរទៅ ។

ខណៈកាលខុងបេង បើកលែងបេងហោក-បេងហ៊ុវទៅផុតហើយ កំលើកទាហានចូលទៅរៀបចំកងទ័ពក្នុងបន្ទាយបេងហោក ហើយបង្គាប់ឲ្យរៀបគ្រឿងអាហារអស់បណ្តានាយទ័ព នាយកង និងពួកទាហាន, លុះបរិភោគរួចអស់ហើយ ទើបខុងបេងនិយាយថា យើងគិតនឹងទំនុកបម្រុងផែនដីព្រះចៅឡៅសៀន ឲ្យបានសុខចម្រើនតទៅ បានជាត្រូវខិតខំតាំងម៉ឹះ, អស់អ្នកតាំងនេះ ដែលបានឯកច្បាំងនឿយហត់ បើមិនគិតឲ្យដឹងគំនិតចិត្តថា ចាប់បានបេងហោក-បេងហ៊ុវហើយ ហេតុម្តេចបានជាបើកលែងទៅវិញជាច្រើនដងច្រើនសានោះ ព្រោះយើងឃើញថា បេង-ហោក នេះជាចៅហ្វាយស្រុក ៗ ក្រៅ ចិត្តកម្លៅរឹងរូសខុសនិងមនុស្សស្រុកយើង, ដែលចាប់បានខ្លួនមកហើយ វាក៏នៅចម្លើយមិនព្រមទទួលសារភាពចំណុះចុះចាញ់តែម្តង ដែលយើងចាប់បានម្តងពីរដង ហើយបើកលែងវាទៅវិញនោះ ព្រោះចង់ឲ្យវាតាល់តម្រិះប្រាជ្ញា មានចិត្តអាកោតខ្លាចឯង ៗ តាំងខាងក្នុងតាំងខាងក្រៅ មិនត្រូវឲ្យវានៅប្រកួតអួតថ្វីដៃបាន, បើនឹងប្រមាណយកតែជ័យជម្នះក្តៅ ៗ ហើយត្រឡប់ចូលទៅក្រុងវិញ ដើម្បីនឹងលើកចេញទៅវាយស្រុកខាងព្រះចៅចូកីទៀត ទោះម្តេចម្តា បេងហោកវា

គង់ធ្វៀតលើកទៅប្រទូសរ៉ាយស្រុកយើងពុំខាន, អស់អ្នកទាំងប៉ុន្មាន ត្រូវតែទំយកចិត្តទុកដាក់ធ្វើបេងហោក ឲ្យបាក់បបខូចខ្ចាចពុំអាចនឹងប្រទូស្តដល់យើងតទៅ ទើបយើងនឹងអស់ទុក្ខក្តៅតីក្រោះរ៉ា ។ ពួកទាហានពល់គ្នាបានស្តាប់ ក៏ចាប់ចិត្តគិតឃើញត្រូវណាស់ លើកដៃសំពះថា គំនិតលោកគិតនោះប្រពៃពេក, យើងខ្ញុំសុំទទួលអាសា ត្រាតែវែកទម្លាយរូបកាយមិនស្តាយជីវិតឡើយ ។

ឯបេងហោក-បេងហ៊ុំនោះ លុះទៅដល់ស្រុកងិនខែ ហើយក៏គ្នាន់ក្នាញ់គុំចិត្តណាស់ ទើបរួតរះឲ្យកេណ្ឌទាហាន ៩៣ ខែត្រ ដែលនៅក្រោមបង្គាប់ ឲ្យលើកប្រញាប់ចូលមកព្រមគ្នា រួមគណនាបាន ៥០ ម៉ឺននាក់, ឯនាយទ័ពនាយកងជាមេទាំងប៉ុន្មាននាក់ ក៏ចូលទៅគំនាប់បេងហោកទាំងអស់គ្នាតាមទំនៀម, បេងហោក-បេងហ៊ុំ ក៏ឲ្យត្រួតត្រៀមទាហានបានពេលាហើយ ក៏លើកទៅតាំងនៅក្បែរស៊ួងសៀងយ៉ ។

ខណៈនោះ ទាហានល្បាតបានភតគ្បាតស៊ើបយកសេចក្តីបានច្បាស់ ក៏ចូលទៅក្រាបសំពះប្តឹងខុងបេងថា បេងហោកឲ្យកេណ្ឌទាហានទាំង៩៣ ខែត្របានពល ៥០ ម៉ឺន ហើយលើកមកតាំងនៅស៊ួងសៀងយ៉ ។ ខុងបេងបានឮដូច្នោះ ក៏អស់សំណើចហើយថា អស់អ្នកពល់គ្នាកុំព្រួយវិតក្កឡើយ នឹងទ័ពនោះ ហើយយើងចង់ឲ្យលើកមកទៀតឲ្យច្រើនជាងនេះ ទើបនឹងឃើញតម្រិះយើង, ហើយក៏បង្គាប់នាយទ័ព នាយកងទាំងពួងឲ្យរៀបលើក

ទ័ពរំកិលចូលទៅ ។ ខុងបេង ក៏ឡើងជិះរទេះតូចនាំទាហានសេះ ៥០០ ឲ្យជាអ្នកនាំផ្លូវទៅមុខ, លុះទៅដល់មាត់ស្ទឹងសៀងយី ទន្លេជូឡុង, ម៉ា-កាយ, អ៊ុយអៀន, ទៀវអេក លើកទ័ពមកប្រទះគ្នា, ខុងបេងក៏បង្គាប់ពលយោធាឲ្យទៅកាប់ឈើមកធ្វើផែ ក៏មិនបាន, ទើបសួរលីយីដែលនាំផ្លូវថា យើងនឹងឆ្លងស្ទឹងទៅឥឡូវនេះ ក៏ទញ់ទាល់ណាស់ ព្រោះគ្មានអ្វីជាពាហ-ណៈនាំទៅបាន, តើអ្នកនឹងគិតអានះឃើញប្រកផ្លូវយ៉ាងណា? ។

លីយីឆ្លើយតបថា លើភ្នំខាងជើងមានព្រៃឈើច្រើនណាស់ ឃើញល្មមនឹងកាប់យកមកធ្វើស្ពានឆ្លងទៅបាន ។ ខុងបេង ឮដូច្នេះ ទើបចាត់ទាហាន ៣០.០០០ ឲ្យទៅកាប់ឈើនិងឫស្សីមកចងជាក្បូនផែ ទទឹង ១ សិន (គឺ ៤ ម៉ែត្រ) ធ្វើស្ពាន លើកទាហានឆ្លងទៅ ដល់ត្រើយម្ខាង ទើបឲ្យរៀបធ្វើបន្ទាយធំ ៣ ធ្វើទ្វារចេញចូលត្រង់ស្ពាន ។

ឯបេងហេកតាំងបន្ទាយក្រោមទឹក ឃើញខុងបេងលើកទ័ពឆ្លងមកបាន ក៏នាំទាហានចំនួន ១០ ម៉ឺនលើកឆកវ៉ាយបន្ទាយខុងបេង ។ ឃើញបេងហេកពាក់អាវស្បែករមាស ពាក់មួកក្រហម ជិះក្របីឃ្មៀច ដៃឆ្វេងកាន់ខែល ដៃស្ដាំកាន់ដាវ លើកទាហានទន្ទ្រានចូលមកដូច្នោះ ក៏បញ្ជាឲ្យលើកពលចូលតទឹងបេងហេក ។ កាំខែលដេញពលខ្លួនឲ្យប្រជ្លួនចូលតដៃជាជ្រួលប្រ-បល់, ខុងបេងមើលយល់មិនជារបៀបក្បួនទ័ព ក៏ថយត្រឡប់ចូលបន្ទាយឲ្យបិទទ្វារមាំមួន, បេងហេកឲ្យទាហានខ្លួនទៅស្រែកដៀល ទ្រគោះដេរ

ខុនបេន ត្រង់មុខបន្ទាយជាអ៊ួអរ, ទាហានខុនបេនក៏មានសេចក្ដីខឹងឡើង ជ្រួលច្របល់ពន់ប្រមាណ បាននាំសេចក្ដីនោះទៅជម្រាបខុនបេនថា យើងខ្ញុំសុំយកអាសាចេញទៅច្បាំងនឹងបេនហោក សងសឹកឲ្យបាន, ខុនបេនទើបមានវាចាប្រស្រ័យតបថា បេនហោកជាខ្មាំងសត្រូវផ្សេងស្រុកទេសពីយើង ចំនើងចិត្ត នឹងធ្វើការតែផ្ដេសផ្ដាសមិនតាមក្បួនទ័ព ដូចទម្លាប់ពិជ័យសង្គ្រាម, យើងត្រូវនៅឲ្យស្ងៀម ចាំមើលកលការសិនចុះ បើឃើញមានចន្លោះស្រួលពេលណា សឹមប្រើប្រាជ្ញាឧបាយយកជ័យជម្នះវាតែម្ដង, អ្នកទាំងពួងកុំពាលមើលងាយសត្រូវ, ត្រូវតែនាំគ្នាជួយការពាររក្សាបន្ទាយឲ្យមាំមួនចុះ ។ ទាហានទាំងនោះទទួលបង្គាប់ហើយ ក៏ថយចេញទៅ ។

ឯបេនហោកមិនបានឃើញខុនបេនបញ្ចេញទាហានមកតស៊ោះ ក៏លើកទាហានចូលបន្ទាយ, នៅ ៣ ថ្ងៃទើបខុនបេនឲ្យហៅជូឡុង-អ៊ុយអៀនមកឲ្យបង្គាប់ថា អ្នកទាំង ២ ចូរនាំទាហានចំនួនទៅត្រៀមម្នាង ហើយត្រូវទៅតាំងបន្ទាយ នៅពីមុខបន្ទាយបេនហោក, បើឃើញយើងបណ្ដែតក្លួងទៅកាលណា ត្រូវឲ្យជូឡុង យកទង់ជ័យដោតក្នុងបន្ទាយឲ្យច្រើនគាលណោះជាបែបបញ្ឆោត, ជូឡុង និងអ៊ុយអៀនទទួលបង្គាប់ហើយក៏លើកពលចេញទៅតាំងបន្ទាយ នៅមុខបន្ទាយបេនហោក, ឯអ៊ុយអៀន ឲ្យនាំពលទៅពួនបង្កប់នៅក្នុងព្រៃញាតស្បាត ប្របជើងភ្នំខាងទិសឯកើត ហើយ

ឲ្យជីករំលុងទុកឲ្យច្រើន យកស្លឹកឈើគ្របពីលើមាត់រំលុងកុំឲ្យស្គាល់បាន, ហើយនឹងបានធ្វើការតាមកំណត់ ។

កាលដូច្នេះ និងស៊ុយអៀន លាខុនបេងទៅហើយ លុះពេលយប់ ខុនបេង ក៏បង្គាប់ម៉ាតាយឲ្យលេងភ្លេងបណ្ដើរទៅ ហើយឲ្យចេញទៅពួនបង្កប់នៅក្រៅបន្ទាយខាងទិសឯលិច, ម៉ាតាយ ក៏ទៅធ្វើតាមបង្គាប់គ្រប់ប្រការ ។ ខុនបេង ក៏ឲ្យដុតភ្លើងក្នុងបន្ទាយភ្លឺស្វាងគ្រប់បន្ទាយទាំង ៣ ហើយឲ្យទៀវអេក ចេញទៅពួនបង្កប់ក្រៅបន្ទាយខាងទិសឯជើង, ឯខ្លួនខុនបេង ក៏លើកចេញទៅតាំងទ័ពនៅក្រៅបន្ទាយ ។

ឯបេងហោកនោះ លុះថយទាហានត្រឡប់មកបន្ទាយជាច្រើនថ្ងៃ ឃើញខុនបេងតាំងទ័ពឈ្លប់មាំណាស់ ទើបលើកទាហានទាំងចុំទាំងចាស់មកប្រជុំគ្នាជាច្រើន ដើម្បីនឹងប្លន់បន្ទាយខុនបេង, លុះទាហានកងមុខមកដល់ ឃើញភ្លើងក្នុងបន្ទាយខុនបេងភ្លឺស្វាងច្បាស់ ក៏មិនអាចនឹងចូលប្លន់យកជ័យជម្នះបាន នាំទាហានរៃរង់ទាល់តែព្រឹកព្រហាម, លុះបេងហោកលើកមកថែមចូលនឹងទាហានកងមុខ នាយទាហាននោះក៏ទៅថ្លែងការណ៍ពិតមានឲ្យបេងហោកស្ដាប់គ្រប់ប្រការ, បេងហោកបានឮពាក្យ ទើបគិតថា ខុនបេងលើកទាហានត្រឡប់ទៅវិញហើយជាប្រាកដ បានជាភ្លេងដុតភ្លើងឲ្យយើងសង្ស័យ, ហើយបេងហោកក៏លើកទាហានចូលទៅដល់ឃើញក្នុងបន្ទាយនោះស្ងាត់ឈឹងសូន្យ គ្មានមនុស្សម្នាគ្រប់បន្ទាយទាំង ៣, បេងហោក

កំស្រដីថា ប្រហែលខុនបេងលើករត់ទៅហើយ មុខជាខាតស្បៀងអាហារជាច្រើនណាស់ ។

បេងហ៊ុំជាប្អូនថា ដែលខុនបេងលះបង់ចោលបន្ទាយហើយរត់ទៅនោះ មិនមែនទេ, ប្រហែលគេគិតជាកលឧបាយបញ្ឆោតយើងទេដឹង ? បេងហេកថា ចៅនិយាយនេះ មិនមែនសោះ ដែលថាខុនបេងធ្វើកលទុកនោះ, ប្រហែលស្រុកកាំងតាំងទីងស្រុកហ៊្វូគៅ លើកទ័ពមកវាយស្រុកសែលឈួនជាប្រាកដ គឺខុនបេងមានកំហិតនឹងលើកទ័ពវិលទៅជាការរួតរះ បានជាគ្រឡាស់ធ្វើកលឧបាយទុក ប្រាថ្នានឹងឲ្យយើងមានសង្ស័យមិនឲ្យកៃខែលើកទ័ពតាមទាន់; ហេតុនេះ, គួរយើងនឹងរួសរាន់លើកតាមទៅជាប្រញាប់ចុះ ។

លុះថាហើយ បេងហេក ក៏បែងទាហានឲ្យចូលទៅជញ្ជូនស្បៀងក្នុងបន្ទាយខុនបេងខ្លះ ក្រៅពីនោះ ឲ្យលើកស្រុះកាត់ទៅតាមក្បែរខាត់ស៊ួង ប្រុងនឹងទៅតាមចាប់ខ្លួនខុនបេងឲ្យបាន, លុះបេងហេកប្រមាណនឹងចូងទៅត្រើយម្ខាង ក៏ឃើញបន្ទាយដែលជួឡុងតាំងទុកក្បែរខាត់ព្រៃខ្ទេស៊ួងដោតទង់ទៀវនៅជាច្រើន សម្គាល់ថា បន្ទាយខុនបេងឈប់ស្នាក់នៅទីនោះ ទើបចាត់ទាហានឲ្យទៅកាប់ឈើចងផែចូងតាមទៅ, វេលានោះទទួលកើតខ្យល់ព្យុះខ្លាំងណាស់ ខុនបេងក៏ឲ្យដុតភ្លើងជាសញ្ញាគ្រប់ទាំង ៣ បន្ទាយ ហើយឲ្យទាហានស្រែកហ៊ោវាយហោះគោះគងទូងស្គរ លើក

ទាហានពីគ្រប់ទិសទី ព័ទ្ធចូលមកហាក់បីដូចរលកនៃមហាសមុទ្រធំ ៗ បេងហេកនៅជាកណ្ដាលប្រជុំកងទ័ព ក៏ភ័យញ័រញាប់សព្វសារពាង្គ ទើបស្ទុះឡើងជិះលើក្របី នាំពលឃាតខ្លះស្ទុះបំពារកងទ័ពដែលព័ទ្ធ រត់កាត់តម្រង់ត្រង់ទៅបន្ទាយ ។

ខណៈនោះ ជូឡុង ចូងពីត្រើយនាយមកតាំងទ័ពនៅបន្ទាយបេង-ហេក តាំងពីកណ្ដាលយប់ស្ងាត់ លុះឃើញបេងហេកនាំទាហានរត់ស្កាត់តម្រង់មក ក៏លើកទាហានចេញទៅទទួលនៅមុខបន្ទាយ ។ បេងហេកក្រឡេកឃើញច្បាស់ពីចម្ងាយក៏ភ័យណាស់ ក្រឡាស់រត់គេចតាមផ្លូវទៅខាងទិសឯលិច ដែលម៉ាតៃយព្ទូនបង្កប់នៅនោះ, លុះបេងហេកទៅដល់ម៉ាតាយក៏នាំទាហានចេញស្កាត់ពីមុខ ចូលគ្រលុកតយុទ្ធគ្នាបាន ៩ ក្បួន, បេងហេករងពុំឈ្នះក៏ប្រះរត់ទៅឯជើងត្រង់បន្ទាយទៀវអេក ដែលស្កាត់ចាំ, ទៀវអេកក៏លើកពលពីច្រូង-ស្កាត់ចេញមកហោមព័ទ្ធស្កាត់ចាប់បានខ្លួនបេង-ហ៊ុវ, ឯបេងហេកក៏គេចរត់ស្ទើរទៅទិសឯកើតដល់ទីព្រៃញឹកទឹកថា នឹងគេចទៅតាមច្រកភ្នំ, លុះទៅដល់ទីជម្រំដែលអ៊ុយអៀនជីករណ្ដៅទុកនោះ ក៏ប្រទះនឹងខុងបេងកំពុងបររទេះតូច ១ នាំទាហានមកស្កាត់ពីមុខ, ខុង-បេងក៏មានទំនុកសើចចំអកឲ្យបេងហេកថា ថ្ងៃនេះចៅបេងហេងនឹងធ្លាក់ខ្លួនមកពានលើគ្រោះអាក្រក់ នឹងគេចហក់រត់ទៅឯណាឲ្យរួចខ្លួនសោត។ យើងមកចាំបង្ក្រាបនឹងចាប់ខ្លួនជាយូរហើយ ។

បេងហេកបានស្តាប់ដូច្នោះ  ក៏ប្រះទៅនិយាយនឹងពួកទាហានថា : អាផែងនេះ វាបេះធ្វើកលឧបាយឲ្យយើងចាញ់បញ្ឆោតវាដល់ ៣ គ្រាមកហើយ,  ឲ្យអ្នកពលគ្នាខំមានះចូលប៉ះកាប់វាឲ្យល្អិត  កុំគិតញញើតដៃឲ្យសោះ, ហើយបេងហេក ក៏ដេញពលទាំងអស់ឲ្យទន្ទ្រាន ចូលទៅដោយកម្លាំងតោសោ មិនបានពិចារណា, ទាំងអស់គ្នាក៏ពារទៅលើរលុងធ្លាក់ផុងទៅគ្មានសល់,  ខុងបេងវិលមកបន្ទាយវិញ,  ឯអ៊ុយអៀនដែលពួនបង្កប់នៅទីនោះ លុះឃើញបេងហេកធ្លាក់រលុងក៏លើកទាហានប្រមាណ ១០០ នាក់,  នៅស្ទាក់ចាប់បេងហេកនិងទាហានបង  ហើយនាំខ្លួនទៅជូនខុងបេង ។  កាលខុងបេងត្រឡប់មកបន្ទាយ  ក៏បញ្ចុះបញ្ចូលពួកទាហានបេងហេកបានច្រើនណាស់ ។

ខុងបេងឲ្យត្រួតពិនិត្យមើលទាហានទាំងពួងស្រេចហើយ  ទើបសួរបញ្ជាក់ថា:  ខ្លួនឯងពលគ្នានឹងស្ម័គ្រចិត្តគិតនៅធ្វើការជាមួយនឹងយើងក៏ដោយមិនស្ម័គ្រនឹងនៅក៏ដោយតាមចិត្តចុះ, ពួកទាហានទាំងនោះបានស្តាប់ក៏ពេញអំណរនាំគ្នាក្រាបសំពះអរគុណហើយ ក៏លាទៅទាំងអស់, ខណៈនោះ ទទួលទៀវអេក ចងខ្លួនបេងហ៊ុវចូលទៅជូនខុងបេង ។ ក៏ប្រស្រ័យសួរថា: បងអ្នកឯងធ្វើខុសមោះពុំគាប់, យើងចាប់ខ្លួនបាន៣ដងទៅហើយ អ្នកឯងជាប្អូន  គួរចេញខ្លួនទន្ទ្រានបងឲ្យយល់សេចក្តី  ហេតុអ្វីនៅតែសមគំនិតគ្នាប្រកួតប្រកាន់ធ្វើសង្គ្រាមតទល់នឹងយើងដល់ណាទៅទៀត,  ឥឡូវយើងចាប់

បាន ៤ ដងនឹងគ្រានេះផង, តើខ្លួននឹងនៅទៀតគិតយ៉ាងណា បើតាមជាតិជាតាហានក្លៀវក្លា មិនគួរនឹងប្រាថ្នាឲ្យឃើញមុខគេសោះឡើយ ។

បេងហ៊ុវបានស្ដាប់ហើយក៏ក្រាបសំពះហើយជម្រាបថា: ទោសខ្ញុំបាទគ្រានេះ ដល់ស្លាប់ពិតណាស់, តែសូមលោកម្ចាស់ប្រោសមេត្តាទុកជីវិតម្ដងទៀតចុះ, ខុងបេងថា: ជីវិតអ្នកឯងនោះនៅក្នុងកណ្ដាប់ដៃយើងហើយ, យើងមិនមែនសម្លាប់អ្នកឯងបានតែត្រឹមថ្ងៃនេះទេ, ទោះបីទៅថ្ងៃមុខទៀតយើងក៏គង់នឹងសម្លាប់បាន, វេលានេះ បើអ្នកឯងសុំអាយុជីវិតយើង ។ ក៏អាណិតលើកលែងទៀតចុះ, តែបើខ្លួនត្រឡប់ពីនេះទៅ ត្រូវទៅគិតគូនឹងបងប្រុសឲ្យស្រួលបួល កុំឲ្យធ្លុកធ្លួលគំនិត គិតធ្វើសឹកនឹងយើងទៀតឡើយ, លុះនិយាយហើយ ខុងបេង ក៏ឲ្យស្រាយចំណងបេងហ៊ីវហើយលែងទៅ ។ កាលបេងហ៊ីវក្រោកចេញទៅដល់ខាងក្រៅ, ទទួលអ៊ុយ-អៀននាំខ្លួនបេងហោកទាំងចំណងចូលមក; ខុងបេងឃើញបេងហោក ក៏ខឹងណាស់, និយាយរហ័សថា យើងចាប់បានខ្លួនហើយលែងទៅវិញ ៣ ដងហើយ, ខ្លួនមិនស្គាល់គុណយើង, ខំបះបើងមកធ្វើសង្គ្រាមត, ឥឡូវយើងចាប់បានខ្លួនជា ៤ តំណាមកទៀត, តើខ្លួននឹងគិតប្រការម្ដេច ? បេងហោកឆ្លើយថា: យើងធ្វើសឹកនេះ ព្រោះលោកធ្វើកលកិច្ចជាឧបាយដោយប្រការផ្សេង ៗ ទើបយើងចាញ់, លោកចាប់ខ្លួនយើងបានមកវិញ, មិនមែននឹងចាញ់ដោយពលាការ, បើនឹងស្លាប់ជីវិតសង្ខារ ក៏គួរឲ្យនៅ

ស្តាយណាស់ ព្រោះធ្វើការទីងលោកមិនទាន់ស្រឡះឲ្យពេញថ្លៃដ ។

ខុនបេងបានឮសម្តីបេងហោកថាដូច្នោះ ទើបកែងប្រើមនុស្សឲ្យនាំខ្លួនបេងហោកទៅសម្លាប់ចេញ, ឯបេងហោកនោះម៉្យាង កមិនមានតក់ស្លុតរន្ធត់ភ័យខ្លាចសោះ, នៅមានទឹកមុខថ្លាស្រស់ដូចធម្មតា, ខុនបេងយល់ឃើញអស្ចារ្យក៏គិតថា បេងហោកនេះជាមនុស្សមានចិត្តឃ្លាហាន, បើយើងទឹងសម្លាប់ឲ្យបានក៏មិនជាទីស្រេចការ អាណាប្រជានុរាស្ត្រចំណុះស្រុកក៏ទឹងបែកបាក់ខ្ចាត់ខ្ចាយទៅអស់, បើដូច្នេះ យើងគួរទឹងដោះលែងបេងហោកទៅឲ្យវាធ្វើជាសឹកសត្រូវតទឹងយើងឲ្យអស់ថ្លៃដវាចុះ, ទុកឲ្យព្រមចំណុះចុះបាញ់ពីខ្លួនវា ។ យកស្រុកដែលឡើងតាំងប៉ុន្មាន មកឲ្យយើងឲ្យបាន ។ ទើបខុនបេង ប្រើភាហានឲ្យស្រាយចំណងបេងហោកចេញ, ហើយធ្វើជាអស់អញលំគេញចិត្តយកស្រាមកឲ្យផឹកហើយថា តាំងពីយើងចាប់អ្នកឯងបានគម្រប់ ៤ ដងក្នុងគ្រានេះហើយ, យើងក៏មិនបានធ្វើអន្តរាយ; មេត្រីចិត្តនៃយើង ក៏រសកយកប់រកនអ្នកជាច្រើនណាស់; ហេតុអ្វីអ្នកមិនប្រែថ្លាស់គំនិតគិតមកចុះចូលយើង តាមស្រួលទៅ ។

(នៅមានត)

# រឿង

# គ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ

របស់លោក ក៉ាបិទ្រែណាត តាហ្គ័រ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សល់

## វគ្គទី ១៩

– ស្រីនោះជាអ្នកណា (ដោរដេទ្រូសួរក៉ាមេស្ហ)

– បងប្អូនខ្ញុំ (ក៉ាមេស្ហឆ្លើយ)

– បងប្អូនយ៉ាងម៉េចហ្នឹង ខ្ញុំស្គាល់គ្រួសារឯងទាំងអស់ ហើយខ្ញុំដូចជាមិនដែលបានឃើញនាងនេះម្ដងណាសោះ ។

– គិច ! ដោរដេទ្រូ (អាក់ស្ហាយយាត់ មានរឿងខុះប្រុស ។ គេមិនចូលចិត្តឲ្យគេឯងដឹងទេណា ។

– តើជារឿងអាថ៌កំបាំងរបស់ឯងឬក៉ាមេស្ហ ? (ដោរដេទ្រូសួរ)

– ទីងហើយ ជាអាថ៌កំបាំងរបស់ខ្ញុំ (អ្នកឆ្លើយទាំងអៀនអន់)

– មិនគួរសោះក៉ាមេស្ហ ប៉ុន្តែធ្វើម្ដេច បើខ្ញុំដឹងចំរឿងដែលឯងលាក់នោះតែម្ដង ហើយប្រសិនជាឯងមិនបានស្ដីដណ្ដឹងប្អូនស្រីខ្ញុំ ។ ក៏មិនលូកដៃចូលក្នុងរឿងឯងដែរ ចូរឯងជឿចិត្តខ្ញុំចុះ ហើយខ្ញុំមិនត្រូវការចង់ស្គាល់ញាតិសាលោហិតឯងធ្វើអ្វីដែរ ។

- ការដែលខ្ញុំអាចប្រាប់ឯងបាន ក្នុងការអ្វីទាំងអស់ដែលឯងសង្ស័យមាន តែថា ខ្ញុំនឹងរៀបការជាមួយនឹងនាងហិមណាលិនី ទាំងមានសតិសម្បជញ្ញៈ ស្អាតបរិសុទ្ធ ហើយខ្ញុំមិនដែលមានធ្វើអំពើអ្វីក្បត់នឹងចិត្តនាងឡើយ ។

– ប្រហែលជាពិតមែន ប៉ុន្តែឪពុកម្ដាយរបស់នាងហិមណាលិនីអាច មិនស្របតាមយោបល់ឯង ខ្ញុំចង់សួរឯងតែប៉ុណ្ណោះថា តើឯងជាសាច់ញាតិនឹងនាងនេះមែនឬមិនមែន? ហើយហេតុដូចម្ដេច បានជាឯងយកនាងនេះមកលាក់នៅទីនេះ? ។

– បើនិយាយប្រាប់ឯងដូច ជាហែកកេរ្តិ៍គេ ដែលខ្ញុំត្រូវលាក់ ចុះខ្ញុំនិយាយប៉ុណ្ណឹងហើយមិនទាន់អស់ចិត្តទេឬ ?

– ក្រែងនាងហ្នឹងហើយ ឬដែលឈ្មោះកាមាលា ?

– ហ្នឹងហើយ!

– ឯងមានទុកនាងជាប្រពន្ធឯងទេ ?

– មានមែន ។

– ហ៎ា ចុះម៉េចក៏ឯងថាឲ្យខ្ញុំអស់ចិត្តនឹងពាក្យឯង ប៉ុណ្ណឹង ?

– ណ្ហើយ ! ដោដេទ្រា មានការពិសេសដែល . . . .

(អាក់ស្ហាយនិយាយបែបចំអក )

– ខ្ញុំគ្មានត្រូវការប្រាប់អ្វីក្រៅពីថា ខ្ញុំមិនបានក្បត់ចិត្តនាងហិមណា-

លំទីបុណ្ណោះទេ ពោះជាអ្នកទាំងអស់គ្នាមើលឃើញខាងក្រៅយ៉ាងនេះ ហើយក្តី ហើយពោះជាអ្នកទាំងអស់គ្នាយល់ថាស្រីអំបាញមិញនេះ ជាអ្នក ដោយខ្ញុំក៏មិនត្រូវការជជែកជាមួយនឹងអ្នកដែរ ពុំនោះទេខ្ញុំជាមនុស្សហោល មៀត ប្រសិនជាថា និយាយទៅហើយ ត្រូវអោយសេចក្តីតែត្រឹមរូបខ្ញុំមួយ ប៉ុណ្ណោះ ខ្ញុំមិនកាត់លំតែសោះ ប៉ុន្តែបើសិនខ្ញុំធ្វើឲ្យខូចអនាគតនាងផង នោះ ខ្ញុំមិនព្រមនិយាយជាដាច់ខាត ៗ (ក៏មេស្តានិយាយ)

— ការដែលឯងលាក់នឹងយើង តើឯងបាននិយាយ ប្រាប់ប្អូនយើង ហើយឬនៅ ?

— នៅទេ ចាំដល់រៀបការហើយ ទើបខ្ញុំប្រាប់ បើនាងចង់ដឹងខ្ញុំ ប្រាប់ឥឡូវហ្នឹងក៏បាន ៗ

— ឯងឲ្យខ្ញុំសួរនាងអំបាញមិញតាបើបានទេ ? (ដោះដូរនាសួរ)

— ទេ! ត្រង់ហ្នឹងប្រាកដជាមិនបានហើយ បើឯងយល់ថាខ្ញុំអាក្រក់ ឯងត្រូវតែរៀនតែត្រឹមរូបខ្ញុំមួយប៉ុណ្ណោះ កាមាលាគានបានដងការណ៍អ្នកផង រឿងនេះផងទេ ខ្ញុំមិនត្រូវការយកនាងមកឲ្យឯងសួរដូចមនុស្សព្រោសទេ ៗ

— ណ្ហើយ ខ្ញុំមិនត្រូវការអ្នកណាទៀតទេ ការដែលខ្ញុំចង់ដឹងទាំង ប៉ុន្មាន ខ្ញុំដឹងអស់ហើយ តែបើឯងហ៊ានដាក់ជើងដល់ផ្ទះខ្ញុំទៀត ខ្ញុំប្រាប់ឯង មុនឲ្យហើយ ថាឯងមុខជាគាប់ស្មុគស្មាញនឹងខាង ប៉ុណ្ណឹងទៀត ខ្ញុំហាមដាច់ ឯងត្រូវឈប់ទាក់ទងជាមួយកើនប្អូនស្រីខ្ញុំទៀត នាំអោយខ្ញុំ តាំងសំបុត្រ-

ស្នាម ហើយបើកាលណា មានគេសួរខ្ញុំថា ហេតុម្តេចបានជាហិមណាលិទីមិនរៀបការ ខ្ញុំឆ្លើយថាខ្ញុំមិនព្រមឲ្យ ប៉ុន្តែបើឯងមិនធ្វើឲ្យត្រឹមត្រូវតាមពាក្យខ្ញុំទេ ខ្ញុំនឹងបើកកកាយកញ្ចប់លាមកឯងឲ្យគេដឹងឲ្យអស់ ៗ ឯងត្រូវយល់ឲ្យច្បាស់ថា ការដែលខ្ញុំសំចៃឯងប៉ុណ្ណឹង មិនមែនដោយសារខ្ញុំស្រឡាញ់ឯងទេ គឺដោយសារតែកេរ្តិ៍ឈ្មោះប្អូនខ្ញុំប៉ុណ្ណោះ ហើយចូរចាំឲ្យច្បាស់ ឯងកុំបញ្ចេញពាក្យសំដី ថាឯងស្គាល់ប្អូនខ្ញុំឲ្យសោះ ៗ ខ្ញុំស្គាល់តម្លៃនៃពាក្យសន្យាឯងហើយ ខ្ញុំមិនបាច់សុំឲ្យឯងសន្យាទៀតទេ ប្រសិនជាឯងគោរពពាក្យសន្យាបាន មិនគិតអ្វីក្រៅអំពីការ ការពារកេរ្តិ៍ឈ្មោះឯងទេ ៗ

— នៃ! ជោជេន្ទ្រា! មិនអាណិតកាមេស្ហផងទេឬ? មិនឃើញគ្នាមុខស្ទៀក ទៅហើយទេឬ? មកទៅប៉ុណ្ណឹងបានហើយ ៗ (គាត់ស្ហាយនិយាយ)

អ្នកទាំងពីរនាក់ដើរចេញទៅ ទុកកាមេស្ហនៅក្រុប រកតែធ្វើការអ្វីបន្តិចក៏មិនកើត ៗ មួយសន្ទុះក្រោយមក លុះស្ងាំទឹងបន្តិចអ្នកគិតចុះដើរទៅដើម្បីឲ្យទូលាយខួរក្បាលនឹងស្រាយបញ្ហាដ៏ស្មុគស្មាញនេះ ប៉ុន្តែនាងកាមាលានៅតែម្នាក់ឯង ៗ អ្នកដើរចូលទៅក្នុងបន្ទប់ជិតនោះ ឃើញនាងកាមាលាអង្គុយនៅមាត់បង្អួច មើលមនុស្សដើរចុះឡើងនៅនាផ្លូវ នាងសួរថា :

— អ្នកណាហ្នឹងបង? ពីព្រឹកមិញខ្ញុំឃើញពីរនាក់ហ្នឹងទៅឯសាលាខ្ញុំដែរ គេមករកអ្វី?

ឮដូច្នោះ កាមេស្ហចង់ភ្ញាក់មាត់ស្រែក ប៉ុន្តែគេទប់វិញធ្វើព្រងើយ

— គេចង់ដឹងថា នាងជាបងប្អូននឹងខ្ញុំមែនឬយ៉ាងម៉េច ៗ នាងព្ជូរព្នោះនាងអៀនឡើងមុខក្រហម ៗ

— ខ្ញុំបានប្រាប់គេវិញថា ឥតមានជាប់សាច់ញាតិអ្វីទេ ៗ

នាងទឹកស្ងានថា ក៉ាមេស្ហនិយាយចំអន់នាងលេង នាងក៏ឆ្លើយតប:

— ម៉េចក៏បងនិយាយផ្ដេសផ្ដាសអីចឹង ?

នៅពេលនោះ ក៉ាមេស្ហចង់និយាយរឿងរ៉ាវប្រាប់នាងឲ្យអស់ ប៉ុន្តែនាងស្រែកកាត់ :

- ហ្ន៎! ក្អែកចឹកផ្លែឈើយើងអស់ហើយបង!

នាងរត់ទៅយកពាន ហើយត្រឡប់មករកក៉ាមេស្ហវិញ:

- បងមិនពិសាទៀតទេ ?

នាងដាក់ពានទៅចំពោះមុខក៉ាមេស្ហ ៗ ពុទ្ធោអើយ! ក៉ាមេស្ហបាត់ឃ្លានអស់ទៅហើយ ប៉ុន្តែដោយឃើញនាងខំទៅយកពានមកដាក់ឲ្យ អ្នកក៏យកផ្លែប៉ោម ១ ចំណិតហុចទៅឲ្យនាង ៗ

— បងពិសាមុនទៅ ចាំខ្ញុំញុំាក្រោយ ៗ

ឃើញសេចក្ដីស្វាមីភក្ដិរបស់នាងដ៏ស្មោះចំពោះខ្លួនយ៉ាងនេះ ក៉ា-មេស្ហគយគន់រូបនាង នឹកអាណិតស្ទើរស្រក់ទឹកភ្នែក អ្នករកពាក្យអ្វីនិយាយតបនឹងនាងទៀតមិនកើត ក៏បរិភោគផ្លែឈើនោះទៅ ៗ លុះបរិភោគហើយ អ្នកប្រាប់នាងកាមាលាថា:

- យើងត្រឡប់ទៅផ្ទះវិញល្ងាចនេះហើយ

នាងកាមាណាដាក់ទឹកមុខស្រពោនមួយរំពេច ហើយនិយាយតិចៗថា :

- ខ្ញុំមិនចង់សោះបង

- ចង់ត្រឡប់ទៅសាលារៀនវិញឬ ?

- ទេ ! ទេ ! កុំឲ្យខ្ញុំត្រឡប់ទៅទីនោះទៀត ពួកនិស្សិតនាំគ្នាជជីកសួរខ្ញុំពីរឿងបង ខ្ញុំពិបាកឆ្លើយនឹងគេណាស់ ។

- ឆ្លើយប្រាប់គេថាម៉េចខ្លះទៅហើយ ?

- មានថាម៉េច ! គេចង់ដឹងថា ហេតុអ្វីបានជាបងទុកខ្ញុំឲ្យនៅសាលានៅពេលវិស្សមកាល (មកដល់ត្រង់នេះ នាងហាក់ដូចជាបើកមុខដំបៅម្ដងទៀត នាងអួលដើមក រកនិយាយតទៅទៀតមិនកើត ។

- ចុះម៉េចក៏មិនឆ្លើយថា ខ្ញុំគ្មានត្រូវជាអ្វីនឹងនាងទៅ ?

នាងបោលភ្នែក សំឡក់ក៉ាមេស្ហ

- ម្ដេចក៏បងឲ្យខ្ញុំ ឆ្លើយ ផ្ដេសផ្ដាសអីចឹង ?

ក៉ាមេស្ហមិនដឹងធ្វើម្ដេច រឿងអាថ៌កំបាំងនោះ ទៅជាដង្កូវស៊ីរូងសាច់ឈាមអ្នកទៅហើយ ។ អ្នកចេះតែនឹកមៃក្នុងចិត្តអ្នកថា មិនដឹងជាដេស្ទនាទៅនិយាយយ៉ាងម្ដេចខ្លះប្រាប់ហាមណាលីទេ មិនដឹងជានាងយល់ថាយ៉ាងម្ដេចទៅ ហើយអ្នកនឹងកាត់ទៅតាមត្រង់ប្រាប់នាងថាយ៉ាងម្ដេច

នឹងកើត ? ឱ ! ហិមណាលិនីអើយ ! តើអ្នកអាចរស់នៅឆ្ងាយពីនាង បានឬទេ ? អ្នកចេះតែទោលតែម្នាក់ឯង ហើយដោយអ្នកពិបាកគិតពេក អ្នករកពាក្យអ្វីឆ្លើយក៏មិនកើត ។

ការដែលអ្នកដឹងពិតនោះ គឺថារឿងកាមាលានិងអ្នក មុខជាត្រូវពួក មិត្រ និងពួកបញ្ញាមិត្រគេនិយាយពេញកំពង់មាត់ហើយ ។ អ្នកបាន ធ្វើកំហុសមួយធំណាស់ កាលដែលអ្នកបានប្រាប់គេថា នាងជាប្រពន្ធ អ្នក នៅពេលដែលអ្នកត្រឡប់មកកាល់កត្តាវិញ ។ អ្នកមិនចង់នៅជា មួយនាងតទៅៈទៀតទេ សូម្បីតែមួយថ្ងៃថែម ក៏អ្នកមិនចង់ដែរ ឃើញ រ៉មេហ្ហអង្គុយធ្ងឹងបែបដូចជាគិត នាងកាមាលាសួរថា :

– ព្រួយរឿងអីហ្នឹងបង ? បើថាត្រឡប់ទៅផ្ទះ ខ្ញុំមុខជានឹងទៅតាម បងទេ ។

តែរ៉មេស្ហចង់ធ្វើអ្វី នាងកាមាលាធ្វើតាមទាំងអស់ ការដែលនាងមិន ទទឹងទាស់ ធ្វើឲ្យរ៉មេស្ហរឹតតែអាណិតនាងខ្លាំងថែមទៀត អ្នកមើលមុខ នាងហាក់ដូចជាគ្មានវិញ្ញាណក្នុងខ្លួន ដោយអ្នករវល់តែបណ្ដែតអារម្មណ៍ ទៅឆ្ងាយពេក ពុំបានរកពាក្យឆ្លើយតបនឹងនាងវិញសោះ ។ នាងទ្រាំ មិនបាន សួរថា:

– បងប្រាប់ខ្ញុំឲ្យត្រង់មកមើល បងខឹងព្រោះខ្ញុំមិនព្រមនៅសាលា វិញឬ ? ។

– តាមពិត គឺខ្ញុំចង់និងខ្លួនខ្ញុំទេ ថាហើយអ្នកខំធ្វើបុករកកាយ ដើម្បីឲ្យនាងសប្បាយចិត្ត ។

– មើល៍ នាងទៅសាលា គេបង្រៀនអ្វីខ្លះ ប្រាប់ខ្ញុំផងមើល ។

នាងកាមាលា ខំនិយាយប្រាប់ក៉ាមេស្ហអំពីការដែលនាងបានរៀន នៅសាលាថា៖ គ្រូប្រាប់នាងថាដីមានរាងមូល ក៉ាមេស្ហធ្វើជាមិនជឿ នាងកាមាលាខំបើកភ្នែកធំ ៗ ហើយរត់ទៅយកសៀវភៅ មកបង្ហាញ ក៉ាមេស្ហជាបន្ទាល់ ។

– ម៉េចក៏បងមិនជឿ ក្នុងសៀវភៅដែលខ្ញុំរៀន គេដាក់ថាអីចឹង ៗ

– និយាយបំផ្លើសច្រើនណាស់ ! នៅក្នុងសៀវភៅធំប៉ុណ្ណាទៅ ដែលគេនិយាយថាដូច្នេះ ?

នាងឆ្លើយប្រកែក មិនព្រមចាញ់៖

– មិនមែនក្នុងសៀវភៅធំណាទេបង សៀវភៅនេះនែ! មើល មានទាំងរូបផង ។

នាងនិយាយពីការរៀនសូត្ររួចហើយ នាងនិយាយពីសិស្សស្រី ពីគ្រូ និងអំពីវិន័យរបស់សាលា ប៉ុន្តែក្នុងពេលនោះ ក៉ាមេស្ហ គ្មានឮ អ្វីប៉ុន្មានទេ អារម្មណ៍របស់អ្នករវល់ហោះហើរទៅឆ្ងាយ តែអ្នកចេះតែ ងក់ក្បាល ហាក់ដូចជាបានស្តាប់ហូរហែ ហើយតែកាលណានាងរៀបនឹង និយាយចប់ គេច្បុចចុងពាក្យដើម្បីសួរបន្តិចទៅទៀត មិនយូរប៉ុន្មាន នាង

យល់ថាក៏មេស្ហឥតមានស្តាប់នាងទេ តូចចិត្តណាស់ នាងស្ទុះក្រោកឡើង:

– បងគ្មានស្តាប់ខ្ញុំសោះ !

– កុំខឹង ថ្ងៃនេះខ្ញុំមិនស្រួលខ្លួនទេកាមាលា

– បងឈឺ ! ឈឺអីបង ?

– ឥតឈឺអ្វីធ្ងន់ទេ តែយូរៗរាល់ធ្វើអីចឹងម្តង និយាយតទៅទៀតចុះ ។

បើអីចឹងបងមើលរូបផែនទីរបស់ខ្ញុំ នាងបើកយកគំនូរមកដាក់នៅមុខក៏មេស្ហ, នែ ! បងឃើញទេ ខ្ញុំគូររូបផែនដី ខ្ញុំគូរវង់មូលពីរ ព្រោះយើងមិនអាចមើលជុំវិញមួយឃើញទាំងសងខាងតែម្តងបានទេ ។

ក៏មេស្ហ ធ្វើហាក់ជាគិតបន្តិច រួចឆ្លើយថា:

– បើរបស់នោះសំប៉ែត កំយើងមិនអាចមើលឃើញទាំងសងខាងដែរ ។

នេះហើយជាថ្ងៃទី ១ នៃវិស្សមកាលរបស់នាងកាមាលា ។

## វគ្គទី ២០

ក្រោយពេលដែលកូនប្រុសគាត់ចេញផុតទៅ លោកអាណាដា ចាប៊ីខំបន់ស្រន់ ដើម្បីឲ្យកូនគាត់នាំដំណឹងល្អមកឲ្យគាត់វិញ ទីងឲ្យបានកូស្នាំងអំពីរឿងអាថ៌កំបាំងទាំងប៉ុន្មាន ប៉ុន្តែ លុះគាត់ក្រឡេកឃើញ កូនគាត់ត្រឡប់មកវិញជាមួយអាក់ស្ហាយ គាត់ស្រងាកចិត្ត ។

ជោជេទ្រា— តាមពិត គឺខ្ញុំមិនស្មានថាពុក ទុកឲ្យរ៉ាមេស្ហវាធ្វើអំពើបែបនេះសោះ ប្រសិនជាខ្ញុំដឹងមុន ខ្ញុំមិនមែននាំវាមកឲ្យស្គាល់ពុកទេ ។

អាណាដា បាប៊ូ– ឯងប្រាប់ពុកជាញយ ៗ ថា ឯងសប្បាយចិត្តណាស់បើបានរ៉ាមេស្ហធ្វើប្ដីហិមណាលិនី ហេតុម៉េចបានជាឯងមិនចង់ . . .

— ខ្ញុំគ្មានចង់បង្អាក់ទេ តែធ្វើម្ដេចបើ . . .

— ពុកមិនយល់ពាក្យ "ធ្វើម្ដេចបើ" របស់ឯងទេ មានតែរៀបការឬឈប់ តែប៉ុណ្ណឹង គ្មានត្រូវការធ្វើពាក់កណ្ដាលទេ ។

— ចុះម្ដេចក៏បណ្ដោយឲ្យវាទៅឆ្ងាយម្ល៉េះ ? . . . .

អាក់ស្ហាយពុទ្ធពុកនិងកូនជជែកគ្នា លួចញញឹម

មានការខ្វះ បើទោះជាគេមិនបណ្ដោយ ក៏វាទៅដែរ មិនចាំបាច់រុញថែមទេ ។ ម្យ៉ាងទៀត បើទឹកដោះគោកំពុបដល់ដីទៅហើយ ទោះយំសោកទៅក៏ឥតប្រយោជន៍ដែរ ឥឡូវត្រូវគិតធ្វើអ្វីធ្វើទៅកុំចាំសាញ ។

ចុះឯងបានឃើញរ៉ាមេស្ហដែរ ? (លោកអាណាដា បាប៊ូសួរទាំងពោរពេញដោយសេចក្ដីបារម្ភ )

ជោជេទ្រា— ថ្វីក៏មិនឃើញ ឃើញនៅកណ្ដាលគ្រួសារគេ ឃើញទាំងប្រពន្ធគេទៅទៀត ។

លោកអាណាដា បាប៊ូ ឮតែប៉ុណ្ណោះ ស្ទុតដូចត្រូវកាំរន្ទះ បន្តិចមកទើបគាត់រកទឹកមាត់លេបបាន ហើយបញ្ចេញវាចាសួរ កូនទាំងមិន

សួរដៀផង :

- ប្រពន្ធវា ?

- ហ្នឹងឯង

- អញមិនជឿទេ ប្រពន្ធរបស់វ៉ាមេស្រុកណាទៅ ?

- វ៉ាមេស្រុករបស់ពុកហ្នឹងណា៎ ! ពីព្រឹកមិញ មិនទៅផ្ទះៗ គឺទៅការប្រពន្ធហ្នឹងហើយ !

- ទេ ចុះថាឪពុកវាស្លាប់ រឿងការនោះក៏ខានទៅហើយតើ?

- វាការរួចទៅហើយ បានឪពុកវាស្លាប់ក្រោយ ។

លោកអាណាផា បាប៊ូ តប់ក្បាលខ្លួនគាត់ ព្រោះវាត្រូវគិតចឹងមែនៗ មួយស្របក់មកទៀត ទើបគាត់និយាយថែម :

- បើដូច្នេះ វារៀបការជាមួយហ៊ិមណាលិនម្ដេចបាន ?

- ព្រោះតែអ៊ីចឹងហើយបានជាខ្ញុំថា

- ថាអីថាទៅ បើវ៉ាន់រៀបចំស្រេចប្រុងតែនឹងចូលរោងទៅហើយ តាល់តែទៅប្រាប់គេវិញឲ្យឈប់អស់ទៅ ។

- មិនបាច់ទៅប្រាប់គេឲ្យឈប់ទេ ប្ដូរតែរឿងមួយទៅបានហើយ រឿងឯទៀត ទុកអ៊ីចឹងចុះ (កូនគាត់និយាយ លោកតា រៃបស្រម្ងាំងកាំង)

- អ៊ីទៅ តែរឿងមួយដែលឯងប្ដូរនោះ ?

គ្រាន់តែមើលទៅឃើញហើយ ប្ដូរអី ! ប្ដូរប្ដីណា៎ រកប្ដីម្នាក់ទៀត

មកដាក់ជំនួសទៅ ចប់ទៅហើយ បើមិនធ្វើអីចឹងទេ យើងមុខជាលែង ហ៊ានងើបមើលមុខអ្នកផងចំហើយ ។

ថាហើយ គេងាកទៅមើលមុខអាក់ស្ហាយ អាក់ស្ហាយទុនមុខចុះធ្វើ ឫកស្លុតសុភាព ។

អាណាថា ម៉ាប៊ូ— ឯងទៅរកប្តីឯណាបានទាំងតក់ក្រហល់យ៉ាងនេះ?

ជោដេន្រ្ទា· កុំព្រួយពុក ខ្ញុំរកបានភ្លាម

- ធ្វើម្តេចហ៊ាមណាលិទីព្រម

— តែវាដឹងរឿងកាមេស្ហ វាហួសពីព្រមទៅទៀតផង ។

— អើ ឯងគិតឃើញអ្វីល្អធ្វើទៅចុះ គួរឲ្យស្តាយណាស់មែន ព្រោះថា កាមេស្ហមានគុណសម្បត្តិល្អ មានប្រាជ្ញាឆ្លាតវៃ ជឹងគួរជឹងសមថែមទៀតផង ។ ទើបតែម្សិលមិញសោះ ភញ្ញាបានបង្គំពេក ឲ្យវាទៅទិញផ្ទះមួយសម្រាប់ធ្វើទីសំណាក់ការមេធាវីនៅឯអេតាវ, រួច . . .

- យី កុំគិតដល់ម្ល៉េះពេក វាទិញអីនៅឯណាទិញទៅ ឈប់គិត គិតតែរឿងប្រាប់ហ៊ាមណាលិទីឲ្យវាដឹងផងឯនេះ កុំនាំឲ្យបាត់ពេលវេលា ទឹកដល់ច្រមុះហើយ ។

ជោដេន្រ្ទា ដើរចេញទៅ បន្តិចត្រឡប់មកវិញ នាំទាំងនាងហ៊ាមណាលិទីមកផង ។ អាក់ស្ហាយ គេចចូលទៅបំបាំងខ្លួនក្រោយទូ ។

ដោយជន្រាបគ្នាប់ឲ្យប្អូនអង្គុយចុះ រួចគេទឹកគេពាក្យ នឹងនិយាយឲ្យបាន ស្រួល :

— អូនឯងមានសម្គាល់អ្វីប្លែក លើអាកប្បកិរិយារបស់កែមេស្ហទេ ?

នាងគ្រវីក្បាលបដិសេធ

— អូនឯងមានសង្ស័យថាវាមានរឿងអ្វីទេ បានជាវាសុំផ្អាកអាពាហ៍-ពិពាហ៍ ?

- ខ្ញុំគ្រាន់តែដឹងថា គេមានការ (នាងនិយាយដោយមិនងើបមុខ សោះ)

— អ៊ីចឹងមិនឃើញប្លែកទេ ?

នាងនៅតែគ្រវីក្បាលថាមិនដឹងទៀត ។ អាកប្បកិរិយាប្អូនស្រីនិង លោកតាដែលទុកចិត្តលើកែមេស្ហតាំងនឹងតដល់ធ្វើឲ្យជោរជន្រាទប់កំហឹង មិនបាន ក៏ប្រែកលែងសំដៃឲ្យប្អូនតែម្ដង :

- តាំងរឿងដែលកែមេស្ហវាទៅផ្ទះជាមួយនឹងឪពុកវា ហើយដល់វាត្រ-ឡប់មកគាល់កត្តាវិញ វាសម្ងំស្ងៀមអស់ប៉ុន្មានខែទេ ? វាទៅតួននៅឯ ជារជុំប៉ាកឯនោះ ទាល់តែវាសិយវាជួបនឹងអូនឯង ហើយអូនឯងហៅវា ឲ្យវាមកលេងផ្ទះដូចមុនទៀត ទើបវាមក របៀងនៅផ្ទះ រឿងហ្នឹងមិនបាន ដល់ទៅម្ដងទេ ។ ចុះបើមានរឿងខ្មៅនឹតហើយ. ម្ដេចក៏មិនរកឧបាយ ធ្វើឲ្យបានឃើញច្បាស់ទៅ អ៊ីក៏គ្មានបេះបង់ដឹងអ្វីបន្តិចសោះយ៉ាងនេះ .

ឥឡូវអូនឯងត្រូវស្ដាប់ ហើយជឿការដែលបងនឹងនិយាយប្រាប់អូនៈ "ពីព្រឹកមិញបងទៅឯសាលារៀន បងបានការណ៍ថា កាមេស្វាវាយកប្រពន្ធវាទៅឲ្យដេកនៅសាលា ហើយដល់ពេលវិស្សមកាល វាគិតឲ្យប្រពន្ធវានៅទីនោះទៀត ប៉ុន្តែនៅពេលក្រោយបំផុត អ្នកស្រីចាងហ្វាងសាលាបានប្រាប់វាថា គាត់មិនអាចរក្សាកាមាលា (គឺជាឈ្មោះប្រពន្ធវា) ទៀតបានទេ ព្រោះសាលាត្រូវបិទទ្វារថ្ងៃនេះ ហេតុនេះហើយបានជាកាមាលាត្រូវចេញទៅនៅផ្ទះ ឯងាវដីប៉ាក់ ជាមួយកាមេស្វា ។

បងទៅផ្ទះវា ហើយបងឃើញស្រីនោះ កំពុងតែចិតផ្លែប៉ោមឲ្យកាមេស្វាញ៉ាំ បងបានសួរកាមេស្វាឲ្យប្រាប់រឿងវាបង វាប្រកែក ៗ ប្រសិនជាវាដោះសារថា មិនមែនជាប្រពន្ធវាទេ បងជឿវាទៅហើយ ប៉ុន្តែវាមិនប្រកែក រួចបើឃើញប៉ុណ្ណឹងហើយអូនឯងនៅតែជឿវាទៀតឬ ?

ផោរេដ្រូនា និយាយហើយ នៅសំឡឹងមុខប្អូន ដើម្បីឲ្យនាងឆ្លើយ ប៉ុន្តែនាងមិនឆ្លើយសោះ នាងទៅជាមានមុខស្ងាំង មួយសន្ទុះស្រាប់តែទន់ខ្លួនដួលពីលើកៅអីសន្ទប់មួយរំពេច ។

លោកអាណាជាបាប៊ូ ភ័យស្លុតនឹងកូន គួរឲ្យអាសូរពេក គាត់ស្ទុះទៅលើកត្រកងកូន ទាំងស្រែកផង :

- ផោរេដ្រូនាលើកប្អូនយកទៅដាក់លើកៅអីវែងទៅ យកទឹកមកស្រប់មុខឲ្យប្អូន ឯអាក់ស្សាយ ក៏ខំទៅយកផ្ដិតមួយអកបក់ឲ្យនាងដែរ ។

នាងបើកភ្នែកដឹងខ្លួនឡើងវិញយកក្បាលដៃប្រត់ដើម មានអាការៈវេបថ្លល់ បុន្តែនាងងាកទៅរកឪពុក ហើយនិយាយតិច ៗ ថា:

– សុំពុកឲ្យអាក់ស្រាយថយចេញឲ្យបាត់ទៅ ។

អាក់ស្រាយដឹងខ្លួន ទម្លាក់ផ្តិតចុះ ដកខ្លួនថយទៅល្វែងម្ខាងយ៉ាងរហ័ស ។ លោកអាណាបាប៊ូ អង្គុយអង្អែលសក់កូន ហើយចេះតែដកដង្ហើមធំ ។

– កូនស្រីសំឡាញ់ឪពុក ! កូនស្រីសំឡាញ់ឪពុក !

វេលានោះ ស្រាប់តែភ្នែកនាងហាមណាលនិងពោរពេញទៅដោយទឹកភ្នែក ហើយដើមទ្រូងនាងមានភាពផឹតប៉ោង ៗ នាងខំទប់បាំងមុខដើម្បីកុំឲ្យអ្នកដទៃមើលឃើញទុក្ខព្រួយរបស់នាង ។ លោកអាណាដាបាប៊ូអាណិតកូនណាស់ ខំនិយាយលួងលោមកូន :

– ឲ្យគេនិយាយអ្វីក៏និយាយទៅចុះ ពុកស្គាល់ចិត្តកាមេស្ហាហើយ វាមិនមែនអាចក្បត់កូនបៀបនេះកើតទេ ជោរជន្រោចប្រាស់ជាប្រទូមិនខានហើយ ។

ជោរជន្រោចពុះពុកចេះតែនិយាយលួងកូន ដើម្បីកុំឲ្យកូនព្រួយពេកទ្រាំអត់មិនបាន ក៏គំហកឲ្យឪពុក ។

– ពុកកុំមានប្រសាសន៍ឲ្យវាសង្ស័យមតអំពើនោះ បើពុកចង់ជៀសវាងមិនឲ្យវាដឹងពីស្បៀ ទៅថ្ងៃមុខនោះវាតែតែចូលទៅទៀត ។ ឲ្យវាគិត

មើលឲ្យមែនទែនទៅ ។

នាងហិមណាលិនី ឮដូច្នោះខឹងណាស់ ទើបសំឡឹងមុខបងហើយស្តីថា :

- ដកបណា ខ្ញុំមិនទាន់បានពុកម៉ែសួរនិយាយអ្វីពីមាត់គេទេ ខ្ញុំគ្មានជឿអ្នកណាទាំងអស់ ។

ថាហើយ នាងខំក្រោកដើរតម្រង់ទៅក្នុងបន្ទប់ ឪពុកនាងជួយគ្រាកូនរហូតដល់គ្រែដេក ។

- ពុកទុកឲ្យខ្ញុំសម្រាកបន្តិច ពុកអញ្ជើញចេញចុះ ។

- កូនឲ្យយាយមេដោះ មកបក់ឲ្យកូនឬ ?

ទេ នាងសុំកុំឲ្យអ្នកណាមកជិតនាងឡើយ ព្រោះនាងចង់នៅតែម្នាក់ឯង ។ លោកតាអញ្ជើញចូលទៅសម្រាកក្នុងបន្ទប់របស់គាត់ ដែលនៅជាប់នឹងបន្ទប់នាង ។ លោកនឹកដល់ប្រពន្ធលោក ដែលទទួលអនិច្ចកម្មតាំងពីនាងទើបនឹងបានអាយុ ៣ ឆ្នាំម៉្លេះ លោកនឹកដល់សេចក្តីស្មោះត្រង់ដល់ការអត់ធ្មត់នឹងទឹកមុខដ៏រីករាយជាធម្មតារបស់ប្រពន្ធលោក ហើយមានសេចក្តីខ្លោចផ្សាចិត្តអាណិតកូន ដែលតាំងពីម្តាយស្លាប់ចោលទៅនៅតែជាមួយលោក ។ ម្យ៉ាងទៀត នាងហិមណាលិនី នៅពេលដែលនាងចំរើនវ័យធំឡើង នាងរឹតតែដូចម្តាយនាងថែមទៀត ។ លោកខំបន់ព្រះសំពះទេវតា សូមឲ្យលោកជួយគ្រួសគ្រាយ កុំឲ្យមានឧបសគ្គ

កក់ផ្លូវលោកឲ្យសោះ ដើម្បីឲ្យកូនស្រីលោក រស់នៅក្នុងសេចក្ដីសុខ សេចក្ដីសប្បាយ ហើយមុននឹងលោកស្លាប់ លោកចង់ឃើញកូនស្រី លោករស់នៅជាមួយនឹងស្វាមីដែលជាទីគាប់ចិត្តរបស់នាងពេញទៅដោយ សុខភាព ទឹកសព្វគ្រប់ទៅ ទឹកនេត្រាលោកជោរជេលហោមគួរឲ្យអាសូរៗ

តាំងតែពីដើមរៀងមក ជោជេន្រ្ទាតែងតែមើលងាយកម្លាំងចិត្តរបស់ ស្រីភាព លុះមានបញ្ហាបែបនេះកើតឡើង យោបល់ដែលគេយល់ថាសំគិះនោះ ទៅជាត្រូវយ៉ាងពេញទំហឹងទៅវិញ ។ ចុះអ្នកណាៈចះដដែកជា មួយនឹងស្ត្រីយ៉ាងម្ដេចកើតបើឃើញការពិតផ្ទាល់ភ្នែកហើយ នៅតែមិន ព្រមជឿទៀត តែមានជំពាក់ចិត្តហើយគេប្រាប់ថា ពីរនិងពីរត្រូវជាបួន ក៏ មិនជឿដែរ ។ ក្បួនតក្កវិជ្ជា (La logique) និយាយថា តែពណ៌សគឺស ប៉ុន្តែបើមានរឿងស្នេហាមកលាយជាមួយផងនោះពណ៌សមុខជាទៅជាខ្មៅ ហើយ នៅពេលនោះ អាក់ស្នាយដើរលប ៗ ចូលទៅក្នុងបន្ទប់ទទួលភ្ញៀវ ជោជេន្រ្ទាហៅមកវិញ :

- ឯងព្រួសហើយ ធ្វើម៉េចឥឡូវ (ជោជេន្រ្ទាសួរ )

- ម៉េចក៏ហៅខ្ញុំឲ្យចូលក្នុងរឿងហ្នឹងធ្វើអ្វី? មែនទែនទៅខ្ញុំគ្មាននាទីជា អ្វីក្នុងរឿងនេះសោះទេណា ។ ខ្ញុំឈប់និយាយប៉ុន្មានថ្ងៃហើយ ឥឡូវកុំនាំ ខ្ញុំឲ្យរំខានក្នុងរឿងនេះទៀត ។

–ចាំថ្ងៃក្រោយសឹមឯងបន្ទោសខ្ញុំ ។ ឥឡូវនេះ ខ្ញុំគ្មានទឹកឃើញអ្វីក្រៅអំពីទៅនិយាយកម្មេស្ហ ឲ្យរកសារគោពតោសប្រាប់ប្អូនខ្ញុំឲ្យអស់ទៅប៉ុណ្ណោះទេ ។

– ឯងឆ្កួតទេ ឯងស្មានថារក . . .

– បើឲ្យស្រួល ស្រេចតែនិយាយឲ្យរកសារសោរមកឲ្យវិញ ឯងជួយគិតអីចឹងផងទៅមើល ហើយបើបានឆាប់តែតែប្រសើរទៅទៀត ។

(នៅមានត)

## ផ្នែកកំណត់-ប្រវត្តិការណ៍

# ពិធីប្រគល់ព្រះត្រៃបិដកខ្មែរ

ជូនចំពោះមជ្ឈមណ្ឌលពុទ្ធសាសនានៅក្រុងហាលេ
សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់

---

តាមសេចក្ដីរាយហេតុរបស់សហជីវិន មាស កោត-កែវមុំ ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅក្រុងប្រាគ សរសេរផ្ញើមកថ្វាយអ្នកអង្គម្ចាស់រដ្ឋមន្ត្រីក្រសួងការបរទេស ហើយដែលបញ្ជូនសេចក្ដីចម្លងមួយច្បាប់ មកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យនោះ, យើងបានដឹងថា សហជីវិនឯកអគ្គរាជទូតយើងប្រចាំក្រុងប្រាគ បានទទួលកិត្តិយសជាតំណាងរាជរដ្ឋាភិបាលខ្មែរ នាំយកអំណោយគម្ពីរព្រះត្រៃបិដកខ្មែរយើងមួយចប់មាន ១១០ ភាគ ទៅប្រគល់ជូនមជ្ឈមណ្ឌលពុទ្ធសាសនានៅទីក្រុងហាលេ នៅសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ កាលពីថ្ងៃទី ២០ មីនា ១៩៦៩ ។

ពិធីប្រគល់អំណោយនេះ បានប្រព្រឹត្តទៅជាមហោឡារិកនៅក្នុងវិទ្យាធិការដ្ឋាននៃសកលវិទ្យាល័យ ម៉ារ្ទាំង លុកធើរ នៅចំពោះមុខអ្នករាជការអាល្លឺម៉ង់ តំណាងក្រសួងការបរទេស, ក្រសួងអប់រំជាតិ, លោកសាកលវិទ្យាធិការ, លោកស្រីតំណាងសមាគមមិត្តភាពជាមួយ

ប្រទេសអាស៊ីប៉ែកអគ្នេយ៍ និង អស់លោកមហាវិទ្យាធិការជាច្រើនរូប ។

វេលានោះ មានការប្តូរយោបល់គ្នាជាច្រើន អំពីការទាក់ទងខាងវប្បធម៌រវាងប្រទេសកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ជាពិសេស គឺការផ្លាស់ប្តូរឯកសារដែលបោះពុម្ពផ្សាយព្រមទាំងការពិសោធន៍រវាងមជ្ឈមណ្ឌលពុទ្ធសាសនានៅទីក្រុងហាលេ និង វិជ្ជាបានពុទ្ធសាសនបណ្ឌិត្យយើង ។ បន្ទាប់ពីការសន្ទនាជាមេត្រីភាពនេះមក ក៏មានធ្វើពិធីជាផ្លូវការ ដោយមានសុន្ទរកថាបី ថ្លែងបន្តបន្ទាប់គ្នា គឺទី ១ សុន្ទរកថារបស់លោកហោរ្ស៊ីតា តោ ជានាយកផ្នែកសិក្សាអំពីវិទ្យាសាស្ត្របុរាណនៃបូព៌ាប្រទេស, បន្ទាប់មកសុន្ទរកថាលោក វ៉ុលហ៍ ជាសាកលវិទ្យាធិការ និងទីបីសុន្ទរកថាសហជីវិនឯកអគ្គរាជទូតខ្មែរ ។ ក្នុងសុន្ទរកថាទាំងពីររបស់មិត្តអាល្លឺម៉ង់ បានដោយបញ្ជាក់អំពីមិត្តភាពនៃប្រទេសយើងទាំងពីរ ជាពិសេសលោកថ្លែងអំណរព្រះគុណថ្វាយសម្តេចព្រះប្រមុខរដ្ឋខ្មែរ និងអំណរគុណជូនរាជរដ្ឋាភិបាលខ្មែរ ដែលបានធ្វើអំណោយក៏មានទូមសា គឺព្រះត្រៃបិដក ចំពោះមជ្ឈមណ្ឌលពុទ្ធសាសនា នៅប្រទេសលោកក្នុងវេលានេះ ព្រមទាំងជាឧត្តមប្រយោជន៍ ខាងការសិក្សាជាន់ខ្ពស់ នៃសាកលវិទ្យាល័យលោកផង ។

បន្ទាប់ពីសុន្ទរកថាទាំងបីនេះមក លោកសាស្ត្រាចារ្យមេត្តីក បានធ្វើសន្និសីទមួយស្តីអំពីព្រះពុទ្ធសាសនា ដោយលើកយកគោលគំនិតទស្សនៈ

របស់ព្រះពុទ្ធ មកផ្ទៀបផ្ទឹមនឹងទ្រឹស្ដីរបស់លោក កាល់ម៉ាក ។ ក្នុងខនេះ លោកសាស្ត្រាចារ្យមេគ្គីៗ បានបំផុសឲ្យឃើញច្បាស់ថា ព្រះពុទ្ធជាម្ចាស់ បានរកឃើញជាស្រេច នូវតម្រាយដែលជាមូលដ្ឋាននៃលទ្ធិរួមសម្បាច់ ឯលោកកាល់ម៉ាក គ្រាន់តែជាអ្នកដើរតាមតម្រាយនេះ ហើយបង្កបង្កើត ឲ្យទៅជាគោលគំនិតណែនាំក្នុងលទ្ធិនេះឡើងតែប៉ុណ្ណោះ ( Le Bouddha aurait dijà tracé la base du communisme et Marx n' a fait que suivre cette base pour creér les principes directeurs du communisme)

មុននឹងបញ្ចប់ពិធីនេះ លោកវុល្ហ៍ បានយកមេដាយអនុស្សាវរីយ៍ នៃសាកលវិទ្យាល័យរបស់លោក មកបំពាក់ជូនសហជីវិនឯកអគ្គរាជទូត ខ្មែរ ព្រមទាំងមានការជប់លៀងជាកិត្តិយសផង រួចហើយលោកអញ្ជើញ ភ្ញៀវចូលទស្សនា មជ្ឈមណ្ឌលពុទ្ធសាសនាដែលនៅទីនោះ មានតម្កល់ គម្ពីរក្បួនច្បាប់ជាច្រើន ដែលបានទៅពីប្រទេសនានា នៅចុងបូព៌ា ហើយដែលសុទ្ធតែស្ដីពីព្រះពុទ្ធសាសនាទាំងអស់ ។

# ពិធីនមស្ការព្រះសក្យមុនីចេតិយ

ពិធីបុណ្យពិសាខបូជា ជាបុណ្យមួយដ៏ធំក្នុងព្រះពុទ្ធសាសនា ។ បណ្ដាជនខ្មែរពុទ្ធសាសនិក បានប្រារព្ធធ្វើបុណ្យនេះរៀងរាល់ឆ្នាំនៅគ្រប់វត្តអារាមទាំងអស់ក្នុងព្រះរាជាណាចក្រ ។

នៅទីក្រុងភ្នំពេញ, ក្រៅពីពិធីដែលរៀបចំឡើងដោយពុទ្ធបរិស័ទនៅតាមអារាមនានា, ព្រះរាជរដ្ឋាភិបាលបានប្រារព្ធធ្វើបុណ្យនេះ ជាផ្លូវការ នៅទីលានមុខស្ថានីយរជាយស្វ័យយាន ចំពោះមុខព្រះសក្យមុនីចេតិយ គឺព្រះចេតិយដែលតម្កល់ព្រះសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ។

ពិធីនេះប្រារព្ធឡើងនៅថ្ងៃពេញបូណ៌មីខែពិសាខ ត្រូវនឹងថ្ងៃអាទិត្យទី ១ ខែឧសភា គ.ស. ១៩៦៩ នៅក្រោមព្រះរាជាធិបតីភាពនៃសម្ដេចព្រះប្រមុខរដ្ឋ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភ ដោយមានឥស្សរជនជាន់ខ្ពស់គ្រប់តំណែង ព្រមទាំងអ្នករាជការ អ្នកមុខអ្នកការ ឧបាសកឧបាសិកា ដែលអញ្ជើញមកពីគ្រប់ទិសទីក្នុងក្រុងភ្នំពេញ ចូលរួមដង្ហែព្រះអគ្គមគ្គុទេសក៍ជាតិក្នុងពេលនេះផង ។

វេលាម៉ោង ១៨ គឺនៅពេលដែលសម្ដេចព្រះប្រមុខរដ្ឋ ស្ដេចយាងដល់ ហើយព្រះអង្គទ្រង់បានគោរពព្រះសង្ឃចំនួន ៨០ អង្គដ៏មានសម្ដេចព្រះសង្ឃរាជ សម្ដេចព្រះសង្ឃនាយក សម្ដេចព្រះពោធិវង្ស និងព្រះ

សង្ឃរាជាគណៈ ហាំនាទុក្រមជាសាទិនោះមក ក្រុមក្មេងនៃកងយោធា ចាប់បន្ទឹសព្ទស្លូរឡើងកំដរចម្រៀងដ៏ពិរោះ បទនគររាជរបស់និស្សិតប្រុសស្រីនៃសាកលវិទ្យាល័យវិចិត្រសិល្បៈ ។ ពេលនោះ គ្រហស្ថទាំងអស់ ក៏ទ្រង់សណ្ឋិតនិងក្រោកឈរគោរពភ្លេងជាតិ តមកពីបទនគររាជ អ្នកចម្រៀងក៏សូត្របទសរភញ្ញ ពេលនោះព្រះសង្ឃទាំងអស់ ក៏ទ្រង់សណ្ឋិត និមន្តក្រោកឈរដែរ ឯពួកគ្រហស្ថទាំងអស់ក៏លើកហត្ថប្រណម្យអញ្ជលីឆ្ពោះទៅព្រះសក្យមុនីចេតិយ ដែលពេលនោះ ទង់ជាតិនិងទង់សាសនា បានអណ្តែតឡើងទៅចុងដងទង់បក់រវិចតាមខ្យល់ ហាក់សម្តែងការរីករាយសប្បាយនៃពុទ្ធបរិស័ទក្នុងមហាពិធីនេះ។ លុះចប់ការគោរពទង់ជាតិទង់សាសនានេះហើយ សហជីវិន **អ៊ីច ហុច សាង** ឧបនាយករដ្ឋមន្ត្រីទី ២ ទទួលបន្ទុកក្រសួងមហាផ្ទៃ ធម្មការ និងការប្រស្រ័យជាមួយសភា បានថ្លែងសុន្ទរកថាមួយ សម្តែងអំណរព្រះមហាករុណាធិគុណ នៃសម្តេចព្រះអគ្គពុទ្ធសាសនូបត្ថម្ភ និងអភិវឌ្ឍនាការចំពោះព្រះបរមធាតុ នៃព្រះពុទ្ធជាអម្ចាស់ (សុន្ទរកថានេះ យើងចុះផ្សាយជូនទាំងស្រុងនៅទំព័របន្ទាប់) ។ តពីនេះមកទៀតក៏មានពិធីនមស្ការជាឧឡារិក ដោយមានអាចារ្យម្នាក់សូត្រនាំមុខ ។

បន្ទាប់ពីនេះ សម្តេចឪជាអម្ចាស់ ទ្រង់យាងប្រទក្សិណព្រះសក្យមុនីចេតិយដោយមានព្រះរាជបរិវារ ឥស្សរជននាម៉ឺនសព្វមុខមន្ត្រីគ្រប់តំណែងអញ្ជើញដង្ហែផង និងមានយុវជន-យុវតី, កងរាជតម្រួត កងយោធា

និងភ្នាក់ងារកងការស៊ីវិល ឈរព័ទ្ធជាកិត្តិយសជុំវិញបរិវេណព្រះចេតិយ ដោយបញ្ចេញជ័យឃោសន៍ទ្រុកងរំពងផង ។ គ្រប់បីជុំហើយ សម្តេចឪ ព្រះប្រមុខរដ្ឋ ស្តេចទ្រង់ថ្វាយកម្រងមាលាចំពោះព្រះសារីរិកធាតុ ដែលតម្កល់ក្នុងទីនេះ សម្តែងព្រះរាជវន្ទនកិច្ច ។

ក្រោយពីពេលសម្តេចព្រះអគ្គសាសនូបត្ថម្ភក៍ ស្តេចយាងត្រឡប់វិញហើយ មានរៀបចំធ្វើពិធីវិសាខបូជាជាលំដាប់ ដោយមានព្រះសង្ឃសូត្រវិសាខបូជា និងទេសនាហូតដល់ពេលអធ្រាត្រ ។

លុះព្រឹកឡើងថ្ងៃ ១ រោច ខែពិសាខ ចាប់តាំងពីម៉ោង ៨ និង ៤០ នាទី ក៏មានពិធីដាក់បាត្រព្រះសង្ឃជាផ្លូវការនៅលើវេទិកាបុណ្យចំនួន ៨០ អង្គ ក្រោមព្រះរាជាធិបតីភាពនៃសម្តេចឪ ព្រះប្រមុខរដ្ឋ ។ បន្ទាប់ពីនេះទៀត មានការដាក់បាត្រព្រះសង្ឃ ២៥០០ អង្គ នៅពេញទីសួនបណ្តោយតាមវិថីព្រះកុសុមៈ និងវិថីឧកញ៉ាផុង ក្រោមការរៀបចំនៃពុទ្ធិកសមាគមទាំងបី គឺពុទ្ធិកសមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ សមាគមមិត្តពុទ្ធិកវិទ្យាល័យ និងសមាគមគិលានសង្គ្រោះព្រះមហាក្សត្រិយានី នៅក្រោមកិច្ចចាត់ចែងនៃក្រសួងធម្មការ ។

# សុន្ទរកថា

សហជីវិនឧបនាយករដ្ឋមន្ត្រីទី ២ ទទួលបន្ទុកក្រសួងធម្មការ

ថ្លែងក្នុងឱកាសបុណ្យនមស្ការព្រះសក្យមុនីចេតិយ

(ថ្ងៃទី ១-៥-៦៩)

---

*សូមព្រះតេជៈតម្កល់លើត្បូង*

*សូមព្រះរាជទានក្រាបបង្គំទូលក្រោមល្អងធូលីព្រះបាទ*

*នៃសម្តេចសហជីវិនព្រះប្រមុខរដ្ឋ ជាព្រះឯកអគ្គពុទ្ធសាសនូបត្ថម្ភក៍*

*សូមទ្រង់ជ្រាប ។*

ថ្ងៃនេះជានក្ខត្តឫក្ស ពេញបូណ៌មីវិសាខ ដែលពុទ្ធសាសនិកជនទូទៅ ប្រារព្ធធ្វើពិធីបុណ្យរំឭកដល់អតិលក្ខិតសម័យនៃព្រះសម្ពុទ្ធបរមគ្រូ គឺជាថ្ងៃដែលព្រះអង្គទ្រង់ប្រសូត្រជាជាតិចុងក្រោយបំផុត ថ្ងៃដែលព្រះអង្គទ្រង់បានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ទឹង ជាថ្ងៃដែលព្រះអង្គយាងចូលកាន់ព្រះបរិនិព្វាន ។ បណ្ដាជនខ្មែរទូទាំងប្រទេស ក៏បាន ប្រារព្ធធ្វើពិធីនេះ ជាទំនៀមជាប់រៀងមកគ្រប់វត្តអារាម ។ ទូលព្រះបង្គំជាខ្ញុំទាំងឡាយ មានបីតិរីករាយឥតឧបមាដោយបានឱកាសដង្ហែព្រះប្រមុខរដ្ឋដ៏ជាទីគោរព ជាទីស្នេហាស្មើដោយជីវិតរបស់ខ្លួន គឺអង្គសម្តេចឪជាអម្ចាស់ ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ស្ដេចយាងមកជាព្រះរាជាធិបតី ក្នុងឱកាសដ៏មហោឡារិកនេះ ។ ព្រះរាជវត្តមានរបស់

ព្រះអង្គ រឹងរឹតតែបន្ថែមនូវសក្តិភាពដ៏ច្បាស់ឡើងទៀត បញ្ជាក់អំពីទឹកព្រះចិត្តដ៏សែនត្រជាក់ ក្រាលដណ្តប់ព្រោះព្រំទៅលើសន្តានចិត្តខេមរជនគ្រប់ឋានៈគ្រប់ពេលវេលា ទាំងកិច្ចការកសាងប្រទេសជាតិ, ទាំងការកសាងបុណ្យកុសល តាមវេសនុវាទ នៃព្រះពុទ្ធជាអម្ចាស់ ។

សូមទ្រង់ព្រះមេត្តាប្រោស !

ពិធីបុណ្យនមស្ការព្រះសក្យមុនីចេតិយ ជាពិធីបុណ្យជាតិដែលជាព្រះកេរ្តិ៍ឧត្តមរបស់សម្តេចឪជាម្ចាស់ ដែលព្រះអង្គទ្រង់ប្រោសព្រះរាជទាននូវព្រះសារីរិកធាតុនៃព្រះសម្ពុទ្ធដែលព្រះអង្គបាននាំមកពីប្រទេសស្រីលង្កា នៅគ្រាដែលស្តេចយាងធ្វើព្រះរាជទស្សនកិច្ចនៅប្រទេសនោះ ឲ្យយកមកប្រតិស្ឋាននៅទីងព្រះចេតិយនេះ ។ ព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត ទ្រង់ព្រះមេត្តាប្រោសឲ្យសាងព្រះចេតិយនេះឡើង ហើយទ្រង់ប្រកាសឲ្យធ្វើបុណ្យនមស្ការជាផ្លូវការរៀងរាល់ឆ្នាំ តាំងពី គ.ស. ១៩៥៧ មក ។ ព្រះរាជកេរ្តិ៍ថ្លៃថ្លានេះឯង ក៏បានដិតជាប់ក្នុងសន្តានចិត្តនៃពុទ្ធមាមកជនខ្មែរ ឲ្យរឭកឃើញជានិច្ច នូវព្រះករុណាធិគុណប្រពៃពិសេសនេះ ពុំមានភ្លេចមួយគ្រាណាឡើយ ។ ព្រះរាជូបត្ថម្ភ គ្រប់បែបគ្រប់យ៉ាងក្នុងផ្លូវព្រះពុទ្ធសាសនា ទុកដូចជាព្រះអំណោយទានមួយយ៉ាងធំ ខាងផ្លូវប្រាជ្ញា និងផ្លូវបដិបត្តិចំពោះបណ្តាជនខ្មែរជាកូនចៅរបស់ព្រះអង្គ ។ ជាភស្តុតាងមួយថ្មីទៀត គឺដោយសារព្រះរាជតម្រិះដ៏ជ្រះថ្លា និងវាងវៃរបស់សម្តេចឪជា

អម្ចាស់ ទ្រង់ត្រាស់បញ្ជាឲ្យក្រសួងធម្មការចាត់ចែងការ ជាមួយក្រសួងនា នា ធ្វើពិធីសម្ពោធព្រះត្រៃបិដកជាផ្លូវការនោះ បណ្ដាជនខ្មែរពេញចិត្តឥតអ្វីប្រៀបផ្ទឹមបាន ហើយក៏នាំគ្នាចាត់ចែងធ្វើពិធីនេះយ៉ាងគគ្រឹកគគ្រេង នៅគ្រប់ទីវត្តអារាមគ្រប់សង្កាត់ គ្រប់ស្រុក គ្រប់ខេត្ត គ្រប់ក្រុង ៗ ដូច្នោះហើយ បានជាគម្ពីរព្រះត្រៃបិដក ដែលរាជរដ្ឋាភិបាលបានចាត់ការបោះពុម្ពតាំងពីច្រើនឆ្នាំមកហើយនោះ មានពុទ្ធបរិស័ទមកជាវយកទៅធ្វើពិធីដង្ហែយ៉ាងអឹកធឹក បើគិតជាប្រាក់បំណុលក្នុងថវិកាជាតិ ដោយការជាវសៀវ-ភៅនេះ ឃើញថាបានចំនួនប្រាំបួនលាន ប្រាំមួយសែនរៀល ហើយសព្វថ្ងៃនេះ ក៏នៅតែមានពុទ្ធបរិស័ទមកជាវជាហូរហែយកទៅតម្កល់ជាក្បួនខ្នាតសម្រាប់សិក្សាប្រចាំវត្តអារាមរៀង ៗ ខ្លួន ៗ សក្ខីភាពម្យ៉ាងទៀតនៃសទ្ធាជ្រះថ្លាយ៉ាងមុះមុតនៃពុទ្ធមាមកជននៅកម្ពុជរដ្ឋ ចំពោះព្រះពុទ្ធសា-សនានោះ គឺនៅពេលដែលក្បួនសម្ពោធព្រះត្រៃបិដក ព័ទ្ធជុំវិញព្រះរាជធានីកាលពីថ្ងៃទី ១ មេសា ១៩៦៩ មានសប្បុរសជន បរិច្ចាគបច្ច័យចូលចាប់កុសលដំគ្រាកាលនេះ រួមទៅបានចំនួន ៧៥៤.០៦៩ រៀល ៗ មិនតែប៉ុណ្ណោះ គោលចារិកព្រះពុទ្ធវចនៈនៅក្នុងព្រះត្រៃបិដក បានជ្រួតជ្រាបសស្រាក់សស្រាំៈ ទៅក្នុងសន្ដានចិត្ត នៃពុទ្ធបរិស័ទខ្មែរយើងកាន់តែខ្លាំងក្លាឡើងទៀត ដូចជាព្រះឱវាទ ដែលសម្ដេចឪជាអម្ចាស់ ទ្រង់បានថ្លែងកាលពីថ្ងៃទី ១ មេសា គ្រាដែលប្រារព្ធពិធីសម្ពោធព្រះត្រៃបិដក នៅទី

លានពុទ្ធិកវិទ្យាល័យ ព្រះសុកម្រិតថា : គម្ពីរក្បួនខ្នាតទាំងនេះ មិន ត្រឹមតែជាគោលសិក្សារបស់ព្រះសង្ឃ នៅគម្ពល់តាមវត្តអារាមប៉ុណ្ណោះទេ អស់លោកជាគ្រហស្ថមានយុវជនជាដើម ក៏ត្រូវមានក្បួនច្បាប់ទាំងនេះ ជាឯកសារផ្ទាល់ខ្លួនដែរ ព្រោះសេចក្ដីទាំងនៃព្រះសទ្ធម្មរបស់ព្រះសម្ពុទ្ធនេះ ហើយ ជាមេគំនិតបណ្ដុះបញ្ញាស្មារតីរបស់យើងឲ្យបានចុះផ្លាស់ក្ដីត្រូវកាល គ្រប់ពេលវេលា ត្រូវតាមគន្លងមនោគមវិជ្ជាជាតិ គឺសង្គមនិយមព្រះពុទ្ធ-សាសនា ។

សូមទ្រង់ព្រះមេត្តាប្រោស

ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមកដវកាស ថ្លែងអភិវន្ទនាការចំពោះ ព្រះសារីរិកធាតុ ដែលមានគម្កល់នៅទីងចេតិយនេះ ដូចតទៅ ។

បពិត្រព្រះអរហន្ត សម្មាសម្ពុទ្ធ បរមគ្រូ

នៅវេលានេះ ខ្ញុំព្រះអង្គទាំងឡាយ ជាពុទ្ធបរិស័ទនៅប្រទេសកម្ពុជា មានសម្ដេចព្រះមហាក្សត្រិយានីបរមបពិត្រ សម្ដេចព្រះប្រមុខរដ្ឋជាអម្ចាស់ សកាទាំងពីរ រាជវង្សានុបាល នាមុខសព្វមុខមន្ត្រីគ្រប់តំណែង មានទាហាន ស៊ីវិល កងពលតម្រួត កងអាសាស្ម័គ្រ និង យុវជន-យុវតី ព្រមទាំងឧបាសក ឧបាសិកា បានមកប្រជុំគ្នា ធ្វើពិធីនមស្ការចំពោះព្រះសារីរិកធាតុរបស់ព្រះ អង្គដើម្បីសម្ដែងនូវព្រះរាជហឫទ័យ និង ទឹកចិត្តគោរពដ៏ជ្រាលជ្រៅ ចំពោះ ព្រះមហាករុណាធិគុណរបស់ព្រះអង្គ ដែលបានទុកព្រះសាសនា ពោល

គឺពាក្យប្រៀនប្រដៅ ចែកចាយដល់យើងខ្ញុំព្រះអង្គគ្រប់គ្នា ៗ រសព្រះសទ្ធម្ម ទុកដូចជាទឹកអម្រឹតប្រោះព្រំបណ្ដុះសតិបញ្ញា ចំពោះយើងខ្ញុំព្រះអង្គគ្រប់ពេលគ្រប់វេលា ព្រមទាំងជាបទដ្ឋានមួយយ៉ាងវិសេសថ្លៃថ្លា ឲ្យមនុស្សលោកទាំងពួងចេះទឹក ឃើញដល់រសជាតិសន្តិភាព សេចក្ដីស្ងប់ក្រៀមក្សាន្ត ជាពិសេសគឺបណ្ដាជនខ្មែរដែលប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួន ថែមទាំងដកស្រង់នូវគោលគំនិតដ៏ល្អប្រពៃទាំងនេះ ធ្វើជាគោលនយោបាយជាតិផង គឺនយោបាយសង្គមនិយមព្រះពុទ្ធសាសនា ដែលសម្ដេចព្រះ**នរោត្តម សីហនុ** ទ្រង់សព្វព្រះរាជហឫទ័យបង្កើតឡើង ដើម្បីញ៉ាំងកម្ពុរដ្ឋឲ្យបានជួបតែនឹងសេចក្ដីសុខ សេចក្ដីចម្រើនរុងរឿង រហូតដល់បានឈ្មោះថាជាកោះសន្តិភាព នៅក្នុងភូមិភាគអាស៊ីប៉ែកអាគ្នេយ៍ ដែលសព្វថ្ងៃច្រើនតែមានក្នក់នរក គឺសង្គ្រាមដុតពេលពលនោះ ៗ ហេតុនេះ សូមសម្ដេចព្រះបរមសាស្ដាសម្មាសម្ពុទ្ធ មេត្តាប្រោសទទួលនូវអភិវន្ទនាការ ព្រមទាំងគ្រឿងសក្ការៈបូជាទាំងឡាយ មានទៀន ធូប ផ្កាភ្ញី ប្រទីបផ្កាលានិង សេចក្ដីគោរពទាំងកាយវាចាចិត្តរបស់យើងខ្ញុំព្រះអង្គ ៗ

សូមទ្រង់ព្រះមេត្តាប្រោស !

ដោយព្រះគុណានុភាពនៃពិធីបុណ្យដែលកើតឡើងក្នុងគ្រានេះ, ទូលព្រះបង្គំជាខ្ញុំសូមថ្វាយនូវព្រះរាជកុសល ចំពោះសម្ដេចព្រះមហាក្សត្រិយានីជាម្ចាស់ជីវិត និង សម្ដេចឪជាម្ចាស់ សូមព្រះអង្គទ្រង់បានប្រកបដោយ

ព្រះបរមសុខសួស្តី មានព្រះជន្មាទីឃាយុយឺនយូរ និង បានឈ្នះអស់មារសត្រូវគ្រប់ទិសទី ដើម្បីបានជាម្លប់យ៉ាងសែនសុខ របស់បណ្តាជនខ្មែរទូទៅ ។

មួយចំណែកទៀត សូមបុញ្ញកុសលនេះ ជួយទ្រទ្រង់សម្តេចព្រះសង្ឃរាជ សម្តេចព្រះសង្ឃនាយក សម្តេចព្រះពោធិវង្ស សូមទ្រង់ប្រកបតែនិងសេចក្តីសុខព្រះកាយពល ផុតចាករោគាពាធផងទាំងពួង ដើម្បីបានទ្រទ្រង់ព្រះពុទ្ធសាសនា ឲ្យរឹងរឹតតែថ្កុំថ្កើងឡើង ។

ទីបំផុត សូមតេជានុភាពនៃកងការកុសលនេះ ជួយឧបត្ថម្ភពុទ្ធបរិស័ទខ្មែរទាំងអស់ ទាំងព្រះសង្ឃទាំងគ្រហស្ថ មាននាម៉ឺនសព្វមុខមន្ត្រី ទាហាន ស៊ីវិល កងពលតម្រួត កងអាសាស្វ័គ្រ យុវជន-យុវតី ជីវពល នារីក្លាហាន និង បណ្តាជនទូទៅ សូមឲ្យបានជួបតែនឹងសេចក្តីសុខ សេចក្តីចំរើនគ្រប់ប្រការ ព្រមទាំងមានចិត្តព្រមព្រៀងគ្នាជាធ្លុងមួយក្នុងការកសាងជាតិ ព្រះពុទ្ធសាសនា និងរាជបល្ល័ង្ក ដង្ហែតាមព្រះមាគ៌ានយោបាយដ៏ភ្លឺស្វាងនៃសម្តេចឪ ព្រះអគ្គមគ្គុទ្ទេសក៍ជាតិ គ្រប់ពេលវេលា តរៀងទៅកុំបីឃ្លាត ។

ជយោ ! សង្គមនិយមព្រះពុទ្ធសាសនា

សូមព្រះតេជៈតម្កល់លើត្បូង !

# សេចក្ដីអំពាវនាវ

## នាកយវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

សូមពិតពុទ្ធដីកា ព្រះតេជព្រះគុណ សូមថ្លៃវិស្សមាជិក ជាសមាជិកា-សមាជិក នៃក្រុមទំនៀមទម្លាប់

សូមជ្រាប ។

កម្មវត្ថុ : អំពីពិធីឡើងពេង និងល្បែងកូនគោលក្មេង ។

មានអ្នកស្រាវជ្រាវបរទេសជាច្រើន ត្រូវការចង់ដឹងឲ្យច្បាស់លាស់ អំពីពិធីឡើងពេង និងល្បែងកូនគោលក្មេង ដែលជាប្រពៃណីនិងទំនៀមទម្លាប់នៃប្រជាពលរដ្ឋខ្មែរយើង ។ ហេតុនេះ ការិយាល័យទំនៀមទម្លាប់ សូមអំពាវនាវដល់ព្រះតេជព្រះ គុណ អស់លោកអ្នក ជាសមាជិកា សមាជិក ក្រុមទំនៀមទម្លាប់ ទាំងអស់នៅគ្រប់ស្រុក គ្រប់ខេត្ត មេត្តាផ្ដល់ពត៌មានអំពីពិធីឡើងពេង និងល្បែងកូនគោលក្មេង ដែលគេធ្លាប់ធ្វើ ធ្លាប់លេងនៅស្រុក ភូមិរបស់ព្រះតេជព្រះគុណ អស់លោក អ្នក តាមសំនួរដូចខាងក្រោមនេះរួចផ្ញើទៅការិយាល័យក្រុមទំនៀមទម្លាប់នៅពុទ្ធសាសនបណ្ឌិត្យ ឲ្យទាន់មុនដាច់ឆ្នាំ ១៩៦៩ នេះ ព្រោះអ្នកស្រាវជ្រាវនោះ គេចង់ទៅមើលដល់ទីកន្លែង និង បានថតរូបផង ។

ឯគោលសេចក្ដីដែលត្រូវឆ្លើយ គឺត្រូវឆ្លើយឲ្យត្រូវ ដូចមានសំនួរតទៅនេះ :

នៅស្រុក ភូមិ ព្រះតេជព្រះគុណ អស់លោក អ្នក មានធ្វើពិធីឡើងពេង និង លេងល្បែងកូនគោលក្មេងនេះដែរ ឬ ទេ? បើមានធ្វើ មានលេង តើគេធ្វើពិធីនោះធំដុំ ឬ តូចតាចទេ?

- គេធ្វើពិធីនេះ នៅ ថ្ងៃ ខែ ណា ? ធ្វើនៅកន្លែងណា (កំណត់យកក្នុងឆ្នាំ ១៩៧០) ។

- សូមប្រាប់ផ្លូវដែលទៅកាន់កន្លែងនោះ តើត្រូវជិះយានអ្វីទើបទៅបាន តើពិបាកទៅ ឬ ឆ្ងាយទៅ ?

- ឯរឿងល្បែងកូនគោលក្មេងក៏ដូចគ្នាដែរ តើគេលេងល្បែងនេះនៅថ្ងៃ-ខែ ណា សព្វថ្ងៃនេះនៅមានគេលេងដែរឬទេ សូមផ្តល់ពត៌មានឲ្យច្បាស់លាស់ ។

សូមព្រះតេជព្រះគុណ សហជីវិនី សហជីវិន មេត្តាឲ្យពត៌មាននេះឲ្យច្បាស់លាស់, ក្រុមទំនៀមទម្លាប់ នឹងចាត់ឲ្យជូនអ្នកស្រាវជ្រាវទាំងនោះ ឲ្យមកពិនិត្យមើលដល់ទីកន្លែង ។

សូមព្រះតេជព្រះគុណ សហជីវិនី សហជីវិន ទទួលនូវសេចក្តីរាប់អានដ៏ស្មោះអំពីខ្ញុំ ។

នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

លាង ហ៊ាប អាន